# សិទ្ធិទទួលការអប់រំ

## វិសាលភាព និង អនុវត្តន៍



យោបល់រួម ១៣ ស្តីពីសិទ្ធិទទួលការអប់រំ
(មាត្រា ១៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពី
សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង សិទ្ធិវប្បធម៌ )


UNESCO

United Nations
Educational, Scientific and
Cultural Organisation

Economic and Social
Council

(ED-2003/WS/73)

# អារម្ភកថា

ការសំរេចជោគជ័យក្នុងការផ្តល់សិទ្ធិទទួលការអប់រំសំរាប់ទាំងអស់គ្នាជាកាតព្វកិច្ចចំពោះមុខមួយដ៏ធំធេងបំផុតសំរាប់យុគសម័យរបស់យើងនេះ។ គោលដៅអភិវឌ្ឍន៍អន្តរជាតិទី២មានបំណងបំពេញកាតព្វកិច្ចនេះឲ្យបានសំរេចគឺធានាធ្វើសកលកម្មអប់រំបឋមសិក្សានៅតាមប្រទេសទាំងអស់ឲ្យបាននៅមុន ឬត្រឹមឆ្នាំ ២០១៥។ គោលបំណងមួយនេះត្រូវបានកំណត់នៅក្នុងវេទិកាអប់រំពិភពលោក (មេសា ២០០០) ដែលក្នុងពេលនោះវេទិកាបានបញ្ជាក់ជំហរឡើងវិញអំពីសិទ្ធិទទួលការអប់រំសំរាប់ទាំងអស់គ្នាថាជាគ្រឹះនៃសិទ្ធិមនុស្ស។

មាត្រា ១៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ មានវិសាលភាពគ្របដណ្តប់លើសិទ្ធិនេះយ៉ាងពេញលេញ និងគ្រប់ជ្រុងជ្រោយបំផុត។ បញ្ញត្តិដែលមានចែងនៅក្នុងនោះជាពង្រាងយោងតាមយោបល់របស់អគ្គនាយករបស់អង្គការ UNESCO។ សិទ្ធិទទួលការអប់រំត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ និងច្បាប់តំបន់ផ្សេងៗទៀតផងដែរ។ ច្បាប់ជាច្រើនទៀតដែលពន្យល់លំអិតដោយអង្គការ UNESCO ទាក់ទងនឹងសិទ្ធិទទួលការអប់រំបង្ហាញនូវស្មារតីច្បាប់ទាក់ទងនឹងសិទ្ធិទទួលការអប់រំនេះក្នុងទិដ្ឋភាពផ្សេងៗទៀត។

សំណួរគ្រឹះដ៏ធំមួយសួរថា តើកាតព្វកិច្ចទាក់ទាក់នឹងសិទ្ធិទទួលការអប់រំដែលត្រូវអនុវត្តដោយរដ្ឋជាសមាជិកក្រោមច្បាប់អន្តរជាតិ និងច្បាប់តំបន់ត្រូវបញ្ចូលក្នុងប្រព័ន្ធច្បាប់ជាតិតាមវិធីណា? សំណួរនេះសំខាន់ជាងគេបំផុតដើម្បីធានាសំរេចគោលដៅក្រុងដាកាក្នុងការធានាអនុវត្តតាមការប្តេជ្ញារបស់រដ្ឋាភិបាលដើម្បីផ្តល់ការអប់រំសំរាប់ទាំងអស់គ្នា ជាពិសេស គឺការអប់រំមូលដ្ឋានប្រកបដោយគុណភាពដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច។ ប៉ុន្តែ ទោះជាមានកាតព្វកិច្ចច្បាប់ និងកិច្ចសន្យានយោបាយយ៉ាងនេះក៏ដោយ ក៏កុមាររាប់លាននាក់មិនមានឱកាសទទួលការអប់រំ ដែលកុមារភាគច្រើនគ្មានឱកាសដោយសារភាពក្រីក្រ។ កុមារទាំងនោះ តាមច្បាប់ ត្រូវទទួលបានការអប់រំមូលដ្ឋាន ដែលជាសិទ្ធិរបស់គេជាពិសេស ការអប់រំបឋមសិក្សា ដែលចែងថា ឥតបង់ថ្លៃ។ ភាពក្រីក្រមិនគួរជាឧបសគ្គរារាំងអ្នកក្រមិនឲ្យទទួលការអប់រំឡើយ ហើយការទាមទាររបស់អ្នកក្រក្នុងការទទួលការអប់រំត្រូវតែទទួលស្គាល់ និងបញ្ចូលក្នុងច្បាប់ដើម្បីអនុវត្តឲ្យបាន។

ការទទួលខុសត្រូវស្ថិតក្រោមបន្ទុករបស់រដ្ឋាភិបាលទាំងស្រុងក្នុងការធានាថា កិច្ចសន្យានយោបាយលើកឡើងក្នុងវេទិកាអប់រំពិភពលោកត្រូវបានបកប្រែឲ្យទៅជាច្បាប់ជាតិ និងជាគោលនយោបាយជាតិតាមប្រទេស។ លទ្ធផលជាផ្លែផ្កាគឺថា មូលដ្ឋានគ្រឹះនៃធម្មនុញ្ញ និងច្បាប់អំពីសិទ្ធិទទួលការអប់រំសន្មត់កំណត់សារៈសំខាន់បន្ថែម ដោយពិចារណាល្អិតល្អន់អំពីផលវិបាកទាក់ទងនឹងច្បាប់ ដោយស្របតាមក្របខ័ណ្ឌសកម្មភាពក្រុងដាកា។ **ការពិភាក្សា**អំពីសិទ្ធិទទួលការអប់រំ និង**ការអនុវត្តបន្ត**ចំពោះអនុសាសន៍របស់វេទិកាអប់រំពិភពលោក (ក្រុងដាកា ខែមេសា ឆ្នាំ ២០០០) រៀបចំដោយគណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ (UNCESCR) ក្រោមកិច្ចសហការជាមួយអង្គការUNESCOនៅថ្ងៃ ១៤ ឧសភា ឆ្នាំ ២០០២។ ការពិភាក្សានោះពិតជាបានបង្ហាញយ៉ាងច្បាស់ថា តើការបញ្ចូលបញ្ញត្តិធម្មនុញ្ញស្តីអំពីសិទ្ធិទទួលការអប់រំ និងស្មារតីច្បាប់សមស្របមានសារៈសំខាន់យ៉ាងណា។ ហេតុដូចនេះ កាតព្វកិច្ចរបស់រដ្ឋាភិបាលនីមួយៗក្រោមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់របស់ប្រទេសនីមួយៗ។

ក្នុងស្មារតីនេះ ចាំបាច់ត្រូវផ្ដល់កំលាំងចលករបន្ថែមដល់សកម្មភាពច្បាប់ដើម្បីធានាអនុវត្តច្បាប់ទាក់ទងនឹងសិទ្ធិទទួលការអប់រំប្រកបដោយប្រសិទ្ធភាព ជាពិសេសសំរាប់អង្គការ UNESCO ហើយព្រមព្រៀងបញ្ចូលសិទ្ធិទទួលការអប់រំមូលដ្ឋានសំរាប់ទាំងអស់គ្នាទៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសនីមួយៗ។ ក្នុងគោលបំណងនេះ កាតព្វកិច្ចដែលត្រូវអនុវត្តដោយរដ្ឋាភិបាលនីមួយៗ និងផលវិបាកដែលអាចកើតឡើងដោយសារការបញ្ចូលសិទ្ធិនេះទៅក្នុងប្រព័ន្ធច្បាប់ជាតិប៉ះពាល់ដល់សកម្មភាព របស់រដ្ឋាភិបាលក្នុងការអនុវត្តការងាររបស់ខ្លួនត្រូវតែទទួលស្គាល់ និងយកចិត្តទុកដាក់បំផុត។ លើសនេះទៀត រដ្ឋជាសមាជិកទាំងអស់នឹងទទួលបានការណែនាំក្នុងការធ្វើរបាយការណ៍ដាក់ជូនអង្គភាពត្រួតពិនិត្យ។

យោបល់ទូទៅលេខ ១៣ នៃមាត្រា ១៣ របស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌បំរើគោលបំណងតែមួយគត់[១]។ យោបល់ទូទៅនេះត្រូវបានពន្យល់លំអិតបន្ថែមដោយគណ:កម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ (UNCESCR) ដោយសហការជាមួយអង្គការ UNESCO។ យោបល់ទូទៅនេះពន្យល់បំភ្លឺអំពីសារ:សំខាន់នៃសិទ្ធិទទួលការអប់រំសំរាប់ធ្វើរបាយការណ៍អំពីការអនុត្ត និងប្រសិទ្ធភាពនៃការអនុវត្ត ដែលជាកាតព្វកិច្ចរបស់រដ្ឋាភិបាលនីមួយៗ។ យោបល់ទូទៅនេះនិយាយអំពីច្បាប់កំណត់ខ្នាតគំរូជាច្រើនរបស់ UNESCO ដូចជា អនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងការទទួលការអប់រំ (១៩៦០) និងសេចក្តីថ្លែងការណ៍សកលលោកស្តីពីអប់រំសំរាប់ទាំងអស់គ្នា (១៩៩០)។ យោបល់ទូទៅនេះក៏ពន្យល់បំភ្លឺបន្ថែមអំពីកាតព្វកិច្ចរបស់រដ្ឋាភិបាលគឺកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិ[២]។ ដូចក្របខ័ណ្ឌសកម្មភាពក្រុងដាកា យោបល់ទូទៅនេះផ្តល់សិទ្ធិទទួលការអប់រំបឋមសិក្សាដោយឥតបង់ថ្លៃ និងដោយកាតព្វកិច្ច ដែលការអប់រំកំរិតនេះត្រូវតែមានរូបរាងជារូបវ័ន្តសំរាប់មនុស្សគ្រប់រូប ហើយបង្គាប់ និងរំលឹកដល់រដ្ឋាភិបាលអំពីកាតព្វកិច្ចដូចមានចែងក្នុងកតិកាសញ្ញាសំរាប់សំរេចគោលដៅជាបណ្តើរៗ។ កាតព្វកិច្ចនេះត្រូវបានបកប្រែសំរាប់អនុវត្តបន្តដើម្បីសំរេចសិទ្ធិទទួលការអប់រំឲ្យមានប្រសិទ្ធភាព និងយ៉ាងឆាប់រហ័ស[៣]។

ក្នុងបរិបទនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ យោបល់ទូទៅលេខ១៣ ស្តីពីសិទ្ធិទទួលការអប់រំគួរបកប្រែឲ្យបានទូលំទូលាយ។ តាមអនុសាសន៍បានពីការពិគ្រោះយោបល់របស់អ្នកជំនាញការក្រៅផ្លូវការស្តីពីសិទ្ធិទទួលការអប់រំរៀបចំដោយអង្គការ UNESCO កាលពីខែ មីនា ឆ្នាំ ២០០១ បានផ្តល់យោបល់ថា ការ អនុវត្តបន្តចំពោះអនុសាសន៍បានពីវេទិកាអប់រំពិភពលោកគួរផ្សាភ្ជាប់ទៅនឹងការអនុវត្តច្បាប់អន្តរជាតិ និងច្បាប់តំបន់។ អ្នកជំនាញការគួសបញ្ជាក់អំពីតម្រូវការសំរាប់ (i) សិក្សាវិភាគអំពីមូលដ្ឋានគ្រឹះនៃក្របខ័ណ្ឌសកម្មភាពក្រុងដាកាក្នុងច្បាប់រដ្ឋធម្មនុញ្ញតាមប្រទេស និងច្បាប់រដ្ឋធម្មនុញ្ញអន្តរជាតិ និង(ii) បង្កើតទំនាក់ទំនងរវាងក្របខ័ណ្ឌសកម្មភាពក្រុងដាកា និងកម្រិងច្បាប់ផ្សេងៗមានជាធរមាន។ លើសនេះទៀត យោងតាមការអនុវត្តបន្តពីវេទិកាអប់រំពិភពលោក ប្រទេសជាសមាជិកគួរកែប្រែច្បាបរបស់ខ្លួនឲ្យទាន់សភាពការណ៍ទំនើបបច្ចុប្បន្ន និងស្របតាមតម្រូវការជាក់ស្តែងរបស់ប្រទេស។

---

១. ចំពោះខ្លឹមសារបន្ថែម និង ការវិភាគអំពីការអនុវត្តមាត្រានេះ អានឯកសារមួយឈ្មោះថា ការអនុត្តអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង សិទ្ធិវប្បធម៌" យោបល់ទូទៅលេខ ១៣ (វគ្គពិភាក្សាលើកទី ២១ របស់គណ:កម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង សិទ្ធិវប្បធម៌ ១៩៩៩) សិទ្ធិទទួលការអប់រំ (មាត្រា ១៣ របស់កតិកាសញ្ញា) ឯកសារ E/E. 12/1999/10, 08 December 1999។
២. Ibid. (para.50)
៣. Ibid. (paras 43 - 44)
៤. របាយការណ៍ត្រួតពិនិត្យការអប់រំសំរាប់ទាំងអស់គ្នាជាសកលឆ្នាំ ២០០២ មានចំណងជើងថា "អប់រំសំរាប់ទាំងអស់គ្នា : តើពិភពលោកដើរតាមផ្លូវត្រឹមត្រូវដែរឬទេ?" បោះពុម្ពដោយអង្គការ UNESCO ឆ្នាំ ២០០២ (ទំព័រ ១៤)។

យោបល់ទូទៅមានសារៈសំខាន់សំរាប់ទាំងការគោរពសិទ្ធិ និងជាពិសេស សំរាប់ការអនុវត្តច្បាប់ជាតិឲ្យកាន់តែមានប្រសិទ្ធភាព។

ពន្យល់លំអិតតែនៅក្នុងបរិបទវេទិកាអប់រំពិភពលោក (ខែមេសា ឆ្នាំ ២០០០) យោបល់ទូទៅនេះជួយលើកកំពស់សុពលភាពបរិបទច្បាប់បច្ចុប្បន្ន បើការយកចិត្តទុកដាក់ផ្តោតទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន។ របាយការណ៍ត្រួតពិនិត្យអប់រំសំរាប់ទាំងអស់គ្នាជាសកលឆ្នាំ ២០០២ មានចំណងជើងថា "អប់រំសំរាប់ទាំងអស់គ្នា : តើពិភពលោកដើរតាមផ្លូវត្រឹមត្រូវដែរឬទេ?" របាយការណ៍នេះគូសបញ្ជាក់អំពីសារៈសំខាន់នៃការប្រើប្រាស់វិធីដោះស្រាយបញ្ហាឈរលើសិទ្ធិមនុស្សជាបន្ថែក។ របាយការណ៍បញ្ជាក់ច្បាស់ថា "កន្លែងណាដែលសិទ្ធិទទួលការអប់រំត្រូវបានធានា កន្លែងនោះប្រជាជនទទួលបានការអប់រំហើយទទួលបានសិទ្ធិផ្សេងៗទៀតផងដែរ[៤]"។ ការគូសបញ្ជាក់នេះជាគំនិតសំខាន់មួយដែលមាននៅក្នុងយោបល់ទូទៅលេខ ១៣ ដែលក្នុងនោះចែងថា ជាដំបូង ការអប់រំមិនត្រឹមតែជាសិទ្ធិមួយប៉ុណ្ណោះទេ ប៉ុន្តែការអប់រំ "ក៏មានសារៈសំខាន់មិនអាចខ្វះបានសំរាប់យកទៅប្រើដើម្បីទទួលសិទ្ធិមនុស្សផ្សេងទៀត"។ ដើម្បីបញ្ចូលវិធីដោះស្រាយបញ្ហាឈរលើសិទ្ធិមនុស្សជាបន្ថែកទៅក្នុងរបាយការណ៍ត្រួតពិនិត្យការអប់រំសំរាប់ទាំងអស់គ្នាប្រចាំឆ្នាំក្រោយៗ យោបល់ទូទៅលេខ១៣ នេះពិតជាមានសារៈសំខាន់មិនអាចខ្វះបាន។

យោបល់ទូទៅនេះក៏មានសារៈសំខាន់សំរាប់ធានាបំពេញបន្ថែមលើចំណុចខ្វះខាតរបស់សហប្រជាជាតិ និងរបស់អង្គភាពត្រួតពិនិត្យសន្ធិសញ្ញា ជាពិសេស ការសហការរបស់អង្គការ UNESCO ជាមួយគណៈកម្មាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ (UNCESCR) ក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្តច្បាប់នានារបស់អង្គការ UNESCO ក្នុងវិស័យអប់រំ។ ហេតុដូចនេះ ចាំបាច់ត្រូវបំផុសឲ្យរដ្ឋជាសមាជិកទាំងអស់គោរពកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិនានា។

យើងមានក្តីសប្បាយរីករាយជាអណោក ដោយសារយើងបានផ្តល់យោបល់សំរាប់យោបល់ទូទៅនេះឲ្យរដ្ឋជាសមាជិកយកចិត្តទុកដាក់លើសារៈសំខាន់ និង តម្លៃសំរាប់អ្នកចែងគោលនយោបាយ និង អង្គភាពនានារបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវលើការតាក់តែងគោលនយោបាយអប់រំជាតិ ក៏ដូចជា ច្បាប់ជាតិពាក់ព័ន្ធផងដែរ។ យើងជឿជាក់លើសមត្ថភាព និង សមត្ថកិច្ចរបស់រដ្ឋាភិបាលក្នុងការកែប្រែសិទ្ធិទទួលការអប់រំមូលដ្ឋានសំរាប់ទាំងអស់គ្នាពីការស្រមៃទៅជាការពិតរស់រវើក។



**John Daniel**
Assistant Director-General for Education,
UNESCO



**Virginia B. Dandan**
Chairperson
United Nations Committee on
Economic, Social and Cultural Rights

# អនុវត្តន៍កតិកាសញ្ញាអន្តរជាតិ
# ស្តីពី
# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង សិទ្ធិវប្បធម៌

*(យោបល់ទូទៅលេខ ១៣)*

# អនុវត្តន៍កតិកាសញ្ញាអន្តរជាតិ
# ស្តីពី
# សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង សិទ្ធិវប្បធម៌

## (យោបល់ទូទៅលេខ ១៣)

***សិទ្ធិទទួលការអប់រំ*** *( មាត្រា ១៣ នៃកតិកាសញ្ញា ) ១/ ១.*

១. *ការអប់រំជាសិទ្ធិមនុស្ស និងជាមធ្យោបាយដ៏សំខាន់ដែលមិនអាចខ្វះបានសំរាប់សំរេចនូវសិទ្ធិមនុស្សផ្សេងៗទៀត។ ជាសិទ្ធិសំរាប់ទទួលសិទ្ធិអំណាចក្នុងការសំរេចចិត្ត ការអប់រំជាយានដ៏សំខាន់មួយដែលមនុស្សពេញវ័យ និងកុមាររស់ក្នុងស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចអាចយកទៅប្រើដើម្បីដឹកដញ្ជូនខ្លួនគេឲ្យចាកផុតពីភាពក្រីក្រ និងទទួលបានមធ្យោបាយផ្សេងៗទៀតដើម្បីចូលរួមក្នុងសហគមន៍ឲ្យបានពេញលេញ។ ការអប់រំមានតួនាទីដ៏សំខាន់ក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ការពារកុមារពីការកេងប្រវ័ញ្ចពលកម្ម និងពីពលកម្មប្រកបដោយគ្រោះថ្នាក់ ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ លើកកំពស់សិទ្ធិមនុស្ស និងប្រជាធិប្បតេយ្យ ការពារបរិស្ថាន និងគ្រប់គ្រងកំណើនប្រជាជន។*

*ជាបន្តបន្ទាប់ ការអប់រំត្រូវបានទទួលស្គាល់ថា ជាវិនិយោគហិរញ្ញវត្ថុដ៏សំខាន់បំផុតមួយដែលរដ្ឋនានាត្រូវតែបណ្តាក់ទុនឲ្យបានច្រើន។ សារៈសំខាន់របស់អប់រំមិនត្រឹមតែថា សំខាន់ប៉ុណ្ណោះទេ តែមានការអប់រំដ៏ប្រសើរ ឆ្លាតវៃ និងសកម្ម អាចប្រកបជីវិតដោយសេរី និងទូលំទូលាយ ហើយសារៈសំខាន់នៃការអប់រំផ្តល់នូវការសប្បាយរីករាយ និងជារង្វាន់ដ៏ប្រពៃរបស់មនុស្សលោក។*

២. *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ (ICESCR) មានមាត្រាពីរនិយាយសំខាន់អំពីសិទ្ធិទទួលការអប់រំ គឺ មាត្រា ១៣ និង១៤។ មាត្រា ១៣ បញ្ញត្តិដែលវែងជាងគេបង្អស់នៅក្នុងកតិកាសញ្ញានោះជាមាត្រាមួយដែលមានអត្ថន័យទូលំទូលាយ និងលំអិតគ្រប់ជ្រុងជ្រោយបំផុតស្តីពីសិទ្ធិទទួលការអប់រំនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គណៈកម្មាធិការបានអនុម័ត* ***យោបល់ទូទៅលេខ ១១*** *នៃមាត្រា ១៤ (ផែនការសកម្មភាពសំរាប់បឋមសិក្សា)។* ***យោបល់ទូទៅលេខ ១១*** *និងយោបល់ទូទៅបច្ចុប្បន្ន គឺបំពេញឲ្យគ្នាទៅវិញទៅមក ហើយយោបល់ទាំងពីរនេះត្រូវយកមកពិចារណារួមគ្នា។ គណៈកម្មាធិការទទួលស្គាល់ថា សំរាប់មនុស្សរាប់លាននាក់នៅទូទាំងពិភពលោក ការទទួលបានសិទ្ធិទទួលការអប់រំដោយពេញចិត្តជាគោលដៅដែលស្ថិតនៅឆ្ងាយដាច់ស្រយាល។ លើសនេះទៀត ក្នុងករណីជាច្រើន គោលដៅនេះកាន់តែឃ្លាតឆ្ងាយទៅៗ ដែលកាន់តែពិបាកសំរេចថែមទៀត។ គណៈកម្មាធិការក៏បានដឹងច្បាស់អំពីការលំបាក និងឧបសគ្គដែលពិបាកដោះស្រាយដែលរារាំងដល់ការអនុវត្តមាត្រា ១៣ នៅបណ្តារដ្ឋនានាផងដែរ។*

៣. ដោយមានទស្សនៈមួយថា ជួយរដ្ឋនានាឲ្យអនុវត្តកតិកាសញ្ញានេះ និងជួយរដ្ឋនានាឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើរបាយការណ៍ យោបល់ទូទៅនេះសង្កត់ធ្ងន់លើខ្លឹមសារខាងគំរូរបស់មាត្រា ១៣ (ផ្នែក I កថាខ័ណ្ឌ ៤-៤២) សង្កត់ធ្ងន់លើកាតព្វកិច្ចមួយចំនួនយកចេញពីមាត្រានេះ (ផ្នែក II កថាខ័ណ្ឌ ៤៣-៥៧) ហើយ សង្កត់ធ្ងន់លើលក្ខខណ្ឌរំលោភច្បាប់មួយចំនួន (ផ្នែក II កថាខ័ណ្ឌ ៥៨-៥៩) ។ ផ្នែក III និយាយអំពីកាតព្វកិច្ចរបស់អ្នកអនុវត្ត ប៉ុន្តែមិននិយាយអំពីកាតព្វកិច្ចរបស់រដ្ឋឡើយ។ យោបល់ទូទៅនេះធ្វើឡើងយោងលើបទពិសោធន៍របស់គណៈកម្មាធិការក្នុងការពិនិត្យវិភាគលើស្ថានភាពរបស់រដ្ឋនានា និងរបាយការណ៍រដ្ឋនានាអស់រយៈពេលជាច្រើនឆ្នាំ។

# I. ខ្លឹមសារនិយាមរបស់មាត្រា ១៣

## មាត្រា ១៣ (១) : គោលបំណង និងទិសដៅរបស់អប់រំ

៤. រដ្ឋនានាឯកភាពថា ការអប់រំទាំងអស់ ទាំងរបស់រដ្ឋ និងរបស់ឯកជន ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ត្រូវសំដៅសំរេចគោលបំណង និងទិសដៅដែលមានកំណត់នៅក្នុងមាត្រា ១៣ (១)។ គណៈកម្មាធិការកត់សំគាល់ថា ទិសដៅអប់រំទាំងនេះគឺឆ្លុះបញ្ចាំង និងវិភាគអំពីគោលបំណង និង **គោលការណ៍** របស់អង្គការសហប្រជាជាតិ ដូចមានចែងក្នុងមាត្រា ១ និង២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ ក្នុងផ្នែកភាគច្រើននៃធម្មនុញ្ញនេះ គោលបំណង និងគោលការណ៍ទាំងនេះក៏មានចែងនៅក្នុងមាត្រា ២៦ (២) នៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្សផងដែរ ទោះជាមាត្រា ១៣ (១) មានបន្ថែមនៅក្នុងសេចក្តីប្រកាសនេះអំពីខ្លឹមសារសំខាន់ៗដូចជា : ការអប់រំត្រូវសំដៅលើកកំពស់ "ភាពថ្លៃថ្នូររបស់មនុស្ស" ការអប់រំត្រូវ "លើកកំពស់សមត្ថភាពរបស់មនុស្សគ្រប់រូបឲ្យចូលរួមក្នុងសង្គមបែបសេរីដោយមានប្រសិទ្ធភាព" ហើយការអប់រំត្រូវតែលើកកំពស់ការយល់ដឹងដល់ "គ្រប់ក្រុមជនជាតិភាគតិច" ក៏ដូចជាក្រុមជនជាតិ និងក្រុមសាសនាផងដែរ។ ក្នុងចំណោមទិសដៅអប់រំទាំងអស់ដែលមានចែងស្រដៀងគ្នាទៅនឹងមាត្រា ២៦ (២) នៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងមាត្រា ១៣ (១) នៃកតិកាសញ្ញានេះប្រហែលជាសំខាន់ជាងគេបំផុតគឺថា "ការអប់រំត្រូវសំដៅធានាអភិវឌ្ឍន៍បុគ្គលភាពរបស់មនុស្សគ្រប់រូប"។

៥. គណៈកម្មាធិការកត់សំគាល់ថា តាំងពីមហាសន្និបាតបានអនុម័តកតិកាសញ្ញានេះនៅឆ្នាំ ១៩៦៦ ច្បាប់អន្តរជាតិផ្សេងៗទៀតក៏បានពន្យល់លំអិតបន្ថែមអំពីទិសដៅទាក់ទងនឹងការអប់រំផងដែរ។ បន្ទាប់មកទៀត គណៈកម្មាធិការយល់ឃើញថា រដ្ឋនានាត្រូវធានាថា ការអប់រំត្រូវអនុវត្តឲ្យស្របតាមគោលបំណង និងទិសដៅដូចមានចែងក្នុងមាត្រា ១៣ (១) ដែលបានបកប្រែនៅក្នុងសេចក្តីថ្លែងការណ៍ពិភពលោកស្តីពីអប់រំសំរាប់ទាំងអស់គ្នា (ជំទៀនប្រទេសថៃ ឆ្នាំ ១៩៩០) (មាត្រា ១) អនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ២៩ (១)) សេចក្តីថ្លែងការណ៍ និងកម្មវិធីសកម្មភាពក្រុងវៀនណា (ផ្នែកទី១ កថាខ័ណ្ឌ ៣៣ និងផ្នែកទី ២ កថាខ័ណ្ឌ ៨០) និងផែនការសកម្មភាពសំរាប់សកម្មភាពទសវត្សរ៍សហប្រជាជាតិស្តីពីការអប់រំសិទ្ធិមនុស្ស(កថាខ័ណ្ឌ២)។ ដោយសារខ្លឹមសារច្បាប់

ទាំងអស់នេះឆ្លើយតបនឹងមាត្រា ១៣ (១) នៃកតិកាសញ្ញានេះ ឯកសារទាំងនេះរួមមានមាតិកាច្បាប់ មួយចំនួនដែលមិនមាននៅក្នុងមាត្រា ១៣ (១) ដូចជាឯកសារទាក់ទងនឹងសមភាពយេនឌ័រ និងការថែរក្សាបរិស្ថាន។ ឯកសារច្បាប់ទាំងនេះមានចែងជាប្រយោល និងបកស្រាយថ្មីៗលើមាត្រា ១៣ (១)។ គណៈកម្មាធិការបានទទួលការគាំទ្រលើទស្សនៈនេះពីគ្រប់មជ្ឈដ្ឋានគឺទទួលបានពីគ្រប់តំបន់ទាំងអស់នៅលើពិភពលោក (១)។

## មាត្រា ១៣ (២) : សិទ្ធិដើម្បីទទួលការអប់រំ – កំណត់សំគាល់ទូទៅមួយចំនួន

៦. ដោយសារការប្រើប្រាស់ពាក្យឲ្យមានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវត្រូវអាស្រ័យលើលក្ខខណ្ឌប្រើប្រាស់នៅតាមប្រទេស ការអប់រំក្នុងគ្រប់ទម្រង់ និងគ្រប់កំរិតទាំងអស់ត្រូវមានលក្ខណៈទាក់ទងនឹងពាក្យចំបងៗខាងក្រោម :

ក) មានធនធានរូបវ័ន្ត : ស្ថាប័ន និងកម្មវិធីអប់រំដែលមានដំណើរការត្រូវតែមានធនធានរូបវ័ន្តគ្រប់គ្រាន់ស្របតាមច្បាប់របស់ប្រទេសនីមួយៗ។ អ្វីដែលស្ថានប័នអប់រំត្រូវការសំរាប់ដំណើរការគឺអាស្រ័យលើកត្តាចំបងជាច្រើន ដូចជា ស្ថានភាពអភិវឌ្ឍន៍នៅក្នុងតំបន់ដែលមានស្ថាប័ន និងកម្មវិធីអប់រំ។ ឧទាហរណ៍ គ្រប់ស្ថាប័ន និងកម្មវិធីអប់រំតែងត្រូវការសំណង់អគារ និងត្រូវការការពារពីគ្រប់ភាគីទាំងអស់ត្រូវការបរិក្ខាអនាម័យសំរាប់មនុស្សទាំងពីរភេទត្រូវការទឹកស្អាតបរិភោគ គ្រូបង្រៀនដែលមានការបណ្តុះបណ្តាល និងទទួលប្រាក់ខែសមស្រប សម្ភារៀន–បង្រៀន។ល។ ស្ថាប័ន និងកម្មវិធីអប់រំខ្លះត្រូវការបរិក្ខាផ្សេងទៀត ដូចជា បណ្ណាល័យ កុំព្យូទ័រ និងប្រព័ន្ធពត៌មានវិទ្យា។

ខ) ឱកាសចូលរៀន : ស្ថាប័ន និងកម្មវិធីអប់រំត្រូវឲ្យមនុស្សគ្រប់រូបមានឱកាសចូលរៀនដោយគ្មានការរើសអើងស្របតាមច្បាប់របស់ប្រទេសនីយមួយៗ។ ឱកាសចូលរៀនមានវិសាលភាពគ្របដណ្តប់លើកត្តាសំខាន់បីគឺ :

i) គ្មានការរើសអើង : តាមច្បាប់ និងតាមការជាក់ស្តែង ការអប់រំត្រូវឲ្យមនុស្សគ្រប់រូបទទួលបានគ្រប់ៗគ្នា ជាពិសេស ក្រុមមនុស្សដែលងាយរងគ្រោះដោយគ្មានការរើសអើងប្រឆាំងនឹងក្រុមមនុស្សណាមួយឡើយ (អានកថាខ័ណ្ឌ ៣១–៣៧ ស្តីពីការមិនរើសអើង)។

ii) ឱកាសចូលរៀនជារូបវ័ន្ធ : ការអប់រំត្រូវស្ថិតក្នុងស្ថានភាពជារូបវ័ន្តមួយ ដែលមនុស្សគ្រប់រូបមានឱកាសចូលរៀនបានប្រកបដោយសុវត្ថិភាពមិនគិតថា ស្ថិតក្នុងតំបន់ភូមិសាស្ត្រឆ្ងាយ (ឧទាហរណ៍ សាលារៀននៅក្បែរភូមិ) ឬ មិនគិតថា តាមរយៈបច្ចេកវិទ្យាទំនើបឡើយ (ឧទាហរណ៍ ឱកាសចូលរៀនការអប់រំពីចំងាយ)។

iii) ឱកាសចូលរៀនអាស្រ័យលើសេដ្ឋកិច្ច ៖ ការអប់រំត្រូវស្ថិតក្នុងតម្លៃមួយដែលមនុស្សគ្រប់រូបមានលទ្ធភាពរកបាន។ ពាក្យថា ឱកាសចូលរៀនក្នុងផ្នែកនេះគឺទាក់ទងនឹងការប្រើប្រាស់ពាក្យខុសគ្នាដូចមានចែងនៅក្នុងមាត្រា ១៣ (២) និយាយអំពីអប់រំបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ ក្នុងន័យនេះ អប់រំបឋមសិក្សាត្រូវមានលក្ខណៈ "ឥតបង់ថ្លៃសំរាប់ទាំងអស់គ្នា"។ គ្រប់ប្រទេសទាំងអស់ត្រូវចាប់ផ្តើមការអប់រំនៅមធ្យមសិក្សា និងឧត្តមសិក្សាដោយឥតបង់ថ្លៃជាបណ្តើរៗ។

គ) អាចទទួលយកបាន ៖ ទម្រង់ និងលក្ខខណ្ឌអប់រំគិតទាំងកម្មវិធីសិក្សា វិធីបង្រៀនត្រូវតែអាចទទួលយកបាន (ឧទាហរណ៍ ពាក់ព័ន្ធនឹងតម្រូវការជាក់ស្តែងអាចទទួលយកបានតាមលក្ខណៈវប្បធម៌ និងប្រកបដោយគុណភាព) សំរាប់សិស្ស និងសំរាប់មាតាបិតាផងដែរ។ កត្តានេះត្រូវស្របតាមវត្ថុបំណងអប់រំដែលមានចែងនៅក្នុងមាត្រា ១៣ (១) និងស្របតាមខ្នាតគំរូអប្បបរិមាអប់រំ ដូចបានអនុម័តតាមប្រទេសនីមួយៗ (អានមាត្រា ១៣ (៣) និង(៤))។

ឃ) អាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្តែង ៖ ការអប់រំត្រូវមានលក្ខណៈទន់ភ្លន់ និងងាយស្រួលកែប្រែ។ ដូចនេះ ការអប់រំអាចកែសំរួលឲ្យស្របតាមតម្រូវការរបស់សង្គម និងសហគមន៍ ហើយការអប់រំអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់សិស្សក្នុងបរិយាកាសសង្គម និងវប្បធម៌ដ៏ស្មុគស្មាញ និងសំបូរបែប។

៧. ដូចនេះ ពេលវិភាគពិចារណាអំពីការប្រតិបត្តិសមស្របទៅលើ "លក្ខខណ្ឌអន្តរទំនាក់ទំនង និងលក្ខខណ្ឌចាំបាច់" ត្រូវវិភាគពិចារណាអំពីតម្រូវការ និងប្រយោជន៍ដ៏ប្រសើររបស់សិស្ស។

## មាត្រា ១៣ (២) (a) ៖ សិទ្ធិទទួលការអប់រំបឋមសិក្សា

៨. អប់រំបឋមសិក្សាគិតបញ្ចូលកត្តាចំបងៗ ដូចជា មានធនធានរូបវ័ន្ត ឱកាសចូលរៀន ការអាចទទួលយកបាន និងការអាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្តែង។ កត្តាទាំងនេះត្រូវបានយល់ជាទូទៅនៅក្នុងបរិបទអប់រំក្នុងគ្រប់ទម្រង់ និងគ្រប់កំរិតទាំងអស់។ (៤)

៩. គណៈកម្មាធិការទទួលការណែនាំអំពីការបកប្រែពាក្យឲ្យសមស្របគឺពាក្យ "បឋមសិក្សា" ដែលដកស្រង់ចេញពីសេចក្តីថ្លែងការណ៍សកលស្តីពីអប់រំសំរាប់ទាំងអស់គ្នាដែលបានចែងថា ៖

"ប្រព័ន្ធផ្តល់ការអប់រំមូលដ្ឋានដល់កុមារដ៏ចំបងក្រៅពីគ្រួសារគឺសាលាបឋមសិក្សា។ អប់រំបឋមសិក្សាត្រូវតែមានលក្ខណៈសកលកម្មដោយធានាថា តម្រូវការរៀនសូត្រជាមូលដ្ឋានរបស់កុមារទាំងអស់ត្រូវល្អគួរជាទីពេញចិត្ត ហើយការអប់រំបឋមសិក្សាត្រូវតែវិភាគពិចារណាអំពីវប្បធម៌ តម្រូវការ និងឱកាសរបស់សហគមន៍" មាត្រា៥។ "តម្រូវការរៀនសូត្រជាមូលដ្ឋាន" មានកំណត់និយមន័យនៅក្នុងមាត្រា ១ នៃសេចក្តីថ្លែងការណ៍សកល។ (៥) ពាក្យថា អប់រំបឋមសិក្សាមិនមានន័យដូចអប់រំមូលដ្ឋានទេ ប៉ុន្តែពាក្យទាំងពីរនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ក្នុងន័យនេះ

គណៈកម្មាធិការបានឯកភាពសំរេចដំហរមួយដែលអនុវត្តដោយ UNICEF : "អប់រំបឋមសិក្សាជាចំណែកដ៏សំខាន់មួយនៃអប់រំមូលដ្ឋាន"។ (៦)

១០. ដូចបានចែងនៅក្នុងមាត្រា ១៣ (២) (a) អប់រំបឋមសិក្សាមានលក្ខខណ្ឌសំខាន់ពីរខុសគ្នាគឺ "អប់រំដោយកាតព្វកិច្ច" និង"អប់រំដែលមានធនធានរូបវិទ្ធដោយឥតបង់ថ្លៃសំរាប់ទាំងអស់គ្នា"។ តាមការអង្កេតរបស់គណៈកម្មាធិការទៅលើពាក្យទាំងនេះ អានកថាខ័ណ្ឌ ៦ និង៧ នៃយោបល់ទូទៅលេខ ១១ នៅមាត្រា ១៤ នៃកតិកាសញ្ញានេះ។

## មាត្រា ១៣ (២) (b) : សិទ្ធិទទួលការអប់រំមធ្យមសិក្សា

១១. អប់រំមធ្យមសិក្សាគិតបញ្ចូលទាំងកត្តាសំខាន់ៗ ដូចជា មានធនធានរូបវិទ្ធ ឱកាសចូលរៀន ការអាចទទួលយកបាន និងការអាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្តែង។ កត្តាទាំងនេះត្រូវបានយល់ជាទូទៅនៅក្នុងបរិបទអប់រំក្នុងគ្រប់ទម្រង់ និងគ្រប់កំរិតទាំងអស់។ (៧)

១២. ដោយសារអប់រំមធ្យមសិក្សាមានលក្ខណៈផ្សេងគ្នាតាមរដ្ឋនីមួយៗ និងតាមពេលវេលាពិតប្រាកដខ្លឹមសារអប់រំមធ្យមសិក្សាត្រូវរាប់បញ្ចូលការបញ្ចប់អប់រំមូលដ្ឋាន និងបញ្ចូលខ្លឹមសារគ្រឹះអំពីការរៀនសូត្រមួយជីវិត និងការអភិវឌ្ឍន៍ធនធានមនុស្ស។ អប់រំមធ្យមសិក្សារៀបចំលក្ខណៈឲ្យសិស្សត្រៀមខ្លួនចូលរៀនវិជ្ជាជីវៈ និងឧត្តមសិក្សា។ ៨/ មាត្រា ១៣ (២) (b) មានវិសាលភាពគ្របដណ្តប់លើអប់រំមធ្យមសិក្សា "ក្នុងទម្រង់ផ្សេងរបស់អប់រំមធ្យមសិក្សា"។ ដូចនេះ មាត្រានេះត្រូវទទួលស្គាល់ថា អប់រំមធ្យមសិក្សាត្រូវការកម្មវិធីសិក្សាដែលមានលក្ខណៈទន់ភ្លន់ និងត្រូវការប្រព័ន្ធផ្តល់ការអប់រំច្រើនប្រភេទដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្សដែលរស់នៅក្នុងស្ថានភាពសង្គម និងស្ថានភាពវប្បធម៌ផ្សេងៗគ្នា។ គណៈកម្មាធិការបំផុសឲ្យមានកម្មវិធីអប់រំ "ផ្សេងៗ" ដែលស្របនឹងប្រព័ន្ធសាលាមធ្យមសិក្សាចំណេះទូទៅ។

១៣. យោងតាមមាត្រា ១៣ (២) (b) អប់រំមធ្យមសិក្សាតាមគ្រប់មធ្យោបាយសមស្រប "ត្រូវផ្តល់លទ្ធភាពឲ្យមនុស្សគ្រប់រូបទទួលបាន ហើយអប់រំមធ្យមសិក្សាត្រូវតែមានធនធានរូបវិទ្ធ"។ ទីមួយ : ឃ្លាថា "មានធនធានរូបវិទ្ធ"បញ្ជាក់ន័យច្បាស់ថា អប់រំមធ្យមសិក្សាមិនមែនអាស្រ័យទាំងស្រុងលើសមត្ថភាព ឬលទ្ធភាពរបស់សិស្សទេ។ ទីពីរ : ឃ្លានេះក៏បញ្ជាក់ន័យថា "អប់រំមធ្យមសិក្សានឹងត្រូវបែងចែកឲ្យគ្រប់ជ្រុងនៃប្រទេសទាំងអស់តាមមធ្យោបាយដែលថា អប់រំមធ្យមសិក្សាត្រូវមានធនធានរូបវិទ្ធក្នុងមូលដ្ឋានដូចៗគ្នាសំរាប់ទាំងអស់គ្នា។ ចំពោះការបកប្រែរបស់គណៈកម្មាធិការទៅលើឃ្លាថា "ឱកាសចូលរៀន" សូមអានកថាខ័ណ្ឌ ៦ ខាងលើ។ ប្រយោគ "គ្រប់មធ្យោបាយសមស្រប" បញ្ជាក់ន័យបន្ថែមត្រង់ចំណុចថា រដ្ឋនានាត្រូវអនុម័តវិធីសាស្ត្រដោះស្រាយបញ្ហាចំរុះ និងថ្មីៗដើម្បីធានាផ្តល់ការអប់រំមធ្យមសិក្សាក្នុងគ្រប់ស្ថានភាពសង្គម និងវប្បធម៌ខុសគ្នា។

១៤. ពាក្យថា "ការណែនាំចាប់ផ្ដើមផ្ដល់ការអប់រំដោយឥតបង់ថ្លៃជាបណ្ដើរ" មានន័យថា រដ្ឋត្រូវកំណត់អាទិភាពផ្ដល់ការអប់រំបឋមសិក្សាដោយឥតបង់ថ្លៃ ហើយរដ្ឋក៏ត្រូវមានកាតព្វកិច្ចចាត់វិធានការជាក់លាក់ និងច្បាស់លាស់ដើម្បីធានាសំរេចអប់រំមធ្យមសិក្សា និងឧត្ដមសិក្សាដោយឥតបង់ថ្លៃ។ តាមការអង្កេតរបស់គណៈកម្មាធិការលើអត្ថន័យនៃពាក្យ "ដោយឥតបង់ថ្លៃ"អានកថាខ័ណ្ឌ ៧ នៃយោបល់ទូទៅលេខ ១១ ក្នុងមាត្រា ១៤។

## អប់រំបច្ចេកទេស និងវិជ្ជាជីវៈ (TVE)

១៥. អប់រំបច្ចេកទេស និងវិជ្ជាជីវៈ (TVE) មានចំណែកទាំងការផ្ដល់សិទ្ធិទទួលការអប់រំ និងសិទ្ធិទទួលការងារ (មាត្រា ៦ (២))។ មាត្រា ១៣ (២) (b) ចាត់ទុក TVE ជាចំណែកមួយនៃការអប់រំមធ្យមសិក្សា ដោយឆ្លុះបញ្ចាំងអំពីសារៈសំខាន់ ជាពិសេសរបស់ TVE នៅក្នុងកំរិតអប់រំមធ្យមសិក្សានេះ។ មាត្រា ៦ (២)មិនចាត់ទុក TVE ចូលក្នុងកំរិតអប់រំណាមួយឡើយ។ មាត្រានេះពន្យល់ច្បាស់ថា TVE មានតួនាទីទូលំទូលាយក្នុងការជួយ "សំរេចការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ដ៏រឹងមាំ ហើយសំរេចបំណងការងារប្រកបដោយផលិតកម្មខ្ពស់"។ សេចក្ដីថ្លែងការណ៍សកលស្ដីពីសិទ្ធិមនុស្សថែងថា "អប់រំបច្ចេកទេស និងវិជ្ជាជីវៈត្រូវតែមានជនធានរូបវ័ន្តទូទៅ" (មាត្រា ២៦ (១)។ ដូចនេះ គណៈកម្មាធិការចាត់ទុកថា TVE ជាចំណែកដ៏សំខាន់មួយនៅគ្រប់កំរិតអប់រំទាំងអស់។(៩)

១៦. ការណែនាំឲ្យស្គាល់បច្ចេកវិទ្យា និងពិភពការងារមិនគួរដាក់បញ្ចូលជាមួយកម្មវិធី TVE ឡើយ ប៉ុន្ដែគួរណែនាំនៅក្នុងកម្មវិធីអប់រំចំណេះទូទៅ។ យោងតាមអនុសញ្ញារបស់ UNESCO ស្ដីពីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (១៩៨៩) TVE ត្រូវមាន "គ្រប់ទម្រង់ និងគ្រប់កំរិតនៃការអប់រំដោយបន្ថែមទៅលើចំណេះទូទៅ ការសិក្សាអំពីបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ និងជំនាញអនុវត្តជំនាញធ្វើ ឥរិយាបថ និងការយល់ដឹងទូទៅទាក់ទងនឹងការងារក្នុងវិស័យនានាសំរាប់ជីវិតសេដ្ឋកិច្ច និងសង្គមកិច្ច" មាត្រា ១ (a)។ ទស្សនៈនេះក៏មានចែងនៅក្នុងអនុសញ្ញា ILO ផងដែរ។ ១០/ សិទ្ធិទទួលការអប់រំបច្ចេកទេស និងវិជ្ជាជីវៈរួមមាន :

ក) ឲ្យសិស្សមានសមត្ថភាពទទួលចំណេះដឹង និងជំនាញដែលអាចរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ភាពស្វ័យម្ចាស់ការ និងលទ្ធភាពរកការងារធ្វើ ហើយ លើកកំពស់សមត្ថភាពផលិតកម្មរបស់គ្រួសារ និងសហគមន៍ គិតទាំងការរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។

ខ) ពិចារណាអំពីសាវតាអប់រំ វប្បធម៌ និងសង្គមកិច្ចរបស់ប្រជាជន ជំនាញ ចំណេះដឹង និងកំរិតសមត្ថភាពបានពីការអប់រំនៅក្នុងវិស័យសេដ្ឋកិច្ច សុខភាពការងារ សុវត្ថិភាព និងសុខុមាលភាព។

គ) ផ្តល់ការបណ្តុះបណ្តាលសារឡើងវិញដល់មនុស្សចាស់ ដែលមានចំណេះដឹង និងជំនាញបែប ចាស់បុរាណទាក់ទងនឹងបច្ចេកវិទ្យា សេដ្ឋកិច្ច ការងារ សង្គមកិច្ច និងជំនាញផ្សេងៗទៀត។

ឃ) មានកម្មវិធី ដែលផ្តល់ឱកាសដល់សិស្ស និស្សិត ជាពិសេសសិស្ស និស្សិតមកពីប្រទេសកំពុង អភិវឌ្ឍក្នុងការទទួលការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅតាមប្រទេសផ្សេងៗក្នុងបំណង កែប្រែ និងផ្ទេរបច្ចេកវិទ្យាឲ្យបានសមស្របតាមតម្រូវការរបស់ប្រទេស។

ង) តាមបរិបទនៃការមិនរើសអើង និងសមភាពនៅក្នុងកតិកាសញ្ញានេះ រួមមានកម្មវិធីលើក កំពស់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈដល់ស្ត្រី កុមារី និងយុវជនក្រៅសាលា យុវជនគ្មាន ការងារធ្វើ កុមារពលកម្ម ជនភៀសខ្លួន ជនពិការ និងក្រុមដែលមិនសូវមានឱកាស។

## មាត្រា ១៣ (២) (c) : សិទ្ធិទទួលការអប់រំនៅឧត្តមសិក្សា

១៧. អប់រំឧត្តមសិក្សាគិតបញ្ចូលទាំងកត្តាសំខាន់ៗ ដូចជា មានធនធានរូបវិន្ត ឱកាសចូលរៀន ការអាច ទទួលយកបាន និងការអាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្តែង។ កត្តាទាំងនេះត្រូវបានយល់ ជាទូទៅនៅក្នុងបរិបទអប់រំក្នុងគ្រប់ទម្រង់ និងគ្រប់កំរិតទាំងអស់។ (១១)

១៨. ទោះជាមាត្រា ១៣ (២) (c) ត្រូវបានរៀបរៀងឡើងស្របនឹងមាត្រា ១៣ (២) (b) ក៏បញ្ញត្តិនៃ មាត្រាទាំងពីរមានភាពខុសគ្នាបីកន្លែង។ មាត្រា១៣ (២)(c) មិនមានញ្ចូលយោងទៅលើការអប់រំ "តាមទម្រង់ផ្សេងគ្នា" ឬទៅលើអប់រំបច្ចេកទេសនិងវិជ្ជាជីវៈទេ។ តាមទស្សនៈរបស់គណៈកម្មាធិការ ការលុបចោលបញ្ញត្តិទាំងពីរនេះគឺគ្រាន់តែបញ្ជាក់អំពីភាពខុសគ្នារវាងមាត្រា ១៣ (២) (b) និង(c) ប៉ុណ្ណោះ។ បើអប់រំឧត្តមសិក្សាត្រូវឆ្លើយតបនឹងតម្រូវការរបស់សិស្សដែលរស់នៅក្នុង ស្ថានភាពសង្គម និងវប្បធម៌ខុសគ្នា អប់រំឧត្តមសិក្សាត្រូវមានកម្មវិធីសិក្សាទន់ភ្លន់ និងប្រព័ន្ធ អប់រំឧត្តមសិក្សាច្រើនសំបូរបែប ដូចជា ប្រព័ន្ធរៀនពីចំងាយ ហើយតាមការអនុវត្តជាក់ស្តែង ការអប់រំមធ្យមសិក្សា និងឧត្តមសិក្សាត្រូវមានធនធានរូបវិន្ត "ក្នុងទម្រង់ផ្សេងៗគ្នា" ដោយសារ កង្វះខាតនៅក្នុងមាត្រា ១៣ (២) យោងទៅលើការអប់រំបច្ចេកទេស និងវិជ្ជាជីវៈដោយយោង មាត្រា ៦ (២) នៃកតិកាសញ្ញានេះ និងមាត្រា ២៦ (១) នៃសេចក្តីប្រកាសសកលស្តីពីអប់រំ បច្ចេកទេស និងវិជ្ជាជីវៈត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់នៃការអប់រំនៅគ្រប់កំរិតទាំងអស់ គិតទាំងឧត្តមសិក្សាផងដែរ។ (១២)

១៩. ការខុសគ្នាទី ៣ និងខុសគ្នាខ្លាំងជាងគេបំផុតរវាងមាត្រា ១៣ (២) (b) និង(c) គឺត្រង់ថា អប់រំ មធ្យមសិក្សា "ត្រូវមានធនធានរូបវិន្តទូទៅ និងមនុស្សគ្រប់ៗរូបអាចទទួលការអប់រំនេះបាន ទាំងអស់គ្នា"។ ចំណែកអប់រំឧត្តមសិក្សា "ត្រូវទទួលបានដោយសមភាពសំរាប់មនុស្សគ្រប់រូប អាស្រ័យលើសមត្ថភាព"។ យោងតាមមាត្រា ១៣ (២) (c) អប់រំឧត្តមសិក្សាមិនទាន់ "មាន ធនធានរូបវិន្តទូទៅនៅឡើយទេ" ប៉ុន្តែ មានធនធានរូបវិន្តសំរាប់ "មនុស្សដែលមានសមត្ថភាព"។ "សមត្ថភាព" របស់មនុស្សម្នាក់ៗ ត្រូវវាយតម្លៃតាមជំនាញ និងបទពិសោធន៍។

២០. រហូតដល់ពេលនេះ ដោយសារពាក្យនៅក្នុងមាត្រា ១៣ (២) (b) និង(c) ដូចគ្នា (ឧ. "ការចាប់ផ្ដើមអនុវត្តការអប់រំដោយឥតបង់ថ្លៃជាបណ្ដើរៗ" អានយោបល់ខាងដើម មាត្រា ១៣ (២) (b)។

## មាត្រា ១៣ (២) (d) : សិទ្ធិទទួលការអប់រំគ្រឹះ

២១. អប់រំមូលដ្ឋានគិតបញ្ចូលទាំងកត្តាសំខាន់ៗ ដូចជា មានធនធានរូបវ័ន្ត ឱកាសចូលរៀន ការអាចទទួលយកបាន និងការអាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្ដែង។ កត្តាទាំងនេះត្រូវបានយល់ជាទូទៅនៅក្នុងបរិបទអប់រំក្នុងគ្រប់ទម្រង់ និងគ្រប់កំរិតទាំងអស់។ (១៣)

២២. តាមពាក្យទូទៅ អប់រំគ្រឹះឆ្លើយតបនឹងពាក្យអប់រំមូលដ្ឋាន ដូចមានចែងនៅក្នុងសេចក្ដីថ្លែងការណ៍សកលលោកស្ដីពីអប់រំសំរាប់ទាំងអស់គ្នា។ (១៤) តាមស្មារតីរបស់មាត្រា ១៣ (២) (d) មនុស្សដែល "មិនបានទទួល ឬមិនបានបញ្ចប់អប់រំបឋមសិក្សា" មានសិទ្ធិទទួលអប់រំគ្រឹះ ឬអប់រំមូលដ្ឋានដូចមានចែងនិងឲ្យនិយមន័យនៅក្នុងសេចក្ដីថ្លែងការណ៍សកលលោកស្ដីពីអប់រំសំរាប់ទាំងអស់គ្នា។

២៣. ដោយសារមនុស្សគ្រប់រូបមានសិទ្ធិទទួល "តម្រូវការអប់រំមូលដ្ឋាន" ដោយពេញចិត្ត ដូចមានចែងនៅក្នុងសេចក្ដីថ្លែងការណ៍សកលលោក សិទ្ធិទទួលការអប់រំគ្រឹះមិនមែនប្រិចាំងនឹងមនុស្សដែល "មិនបានទទួល ឬមិនបានរៀនចប់អប់រំបឋមសិក្សា" នោះទេ។ សិទ្ធិទទួលការអប់រំគ្រឹះមានវិសាលភាពសំរាប់គ្រប់មនុស្សរូបដែលមិនទាន់បានទទួលការពេញចិត្តលើ "តម្រូវការរៀនសូត្រមូលដ្ឋាន"។

២៤. គួរកត់សំគាល់ថា ការបានទទួលសិទ្ធិទទួលការអប់រំគ្រឹះគឺមិនមែនកំណត់តាមអាយុ ឬភេទទេ។ សិទ្ធិនេះមានសំរាប់ទាំងកុមារ យុវជន និងមនុស្សពេញវ័យ គិតទាំងមនុស្សចាស់ជងដែរ។ ដូចនេះអប់រំគ្រឹះជាចំណែកមួយដ៏សំខាន់នៃការអប់រំមនុស្សចាស់ និងការរៀនសូត្រមួយជីវិត។ ដោយសារអប់រំគ្រឹះជាសិទ្ធិមួយរបស់មនុស្សគ្រប់វ័យ កម្មវិធីសិក្សា និងប្រព័ន្ធផ្ដល់ការអប់រំនេះត្រូវតែមានលក្ខណៈទន់ភ្លន់ ដែលសមស្របសំរាប់អ្នករៀនសូត្រគ្រប់វ័យ។

## មាត្រា ១៣ (២) (e) : ប្រព័ន្ធសាលារៀន ប្រព័ន្ធអាហារូបករណ៍គ្រប់គ្រាន់ លក្ខខណ្ឌសម្ភាររបស់គ្រូបង្រៀន

២៥. តម្រូវការដែលថា ការអភិវឌ្ឍន៍ប្រព័ន្ធសាលារៀននៅគ្រប់កំរិតទាំងអស់ត្រូវតែជាមធ្យោបាយដ៏សកម្មដែលគ្រប់រដ្ឋទាំងអស់ត្រូវកំណត់ឲ្យបាននូវយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍប្រព័ន្ធសាលារៀន។ យុទ្ធសាស្ត្រនោះត្រូវដាក់បញ្ចូលសាលារៀននៅគ្រប់កំរិតទាំងអស់ ប៉ុន្តែ កតិកាសញ្ញានេះទាមទារឲ្យរដ្ឋទាំងអស់កំណត់អាទិភាពអប់រំបឋមសិក្សា (អានកថាខ័ណ្ឌ ៥១)។ "បន្តផ្ដល់យោបល់យ៉ាងសកម្មថា" យុទ្ធសាស្ត្ររួមត្រូវទាក់ទាញនូវកំរិតអាទិភាពរបស់រដ្ឋាភិបាល ហើយក្នុងករណីណាមួយត្រូវអនុវត្តឲ្យអស់ពីកំលាំង និងសមត្ថភាព។

២៦. តម្រូវការដែលថា "ត្រូវបង្កើតប្រព័ន្ធអាហារូបករណ៍គ្រប់គ្រាន់" មានបញ្ចូលនៅក្នុងបញ្ញត្តិស្តីពីការមិនរើសអើង និងសមភាពក្នុងកតិកាសញ្ញានេះ។ ប្រព័ន្ធអាហារូបករណ៍ត្រូវលើកកំពស់ឱកាសចូលរៀនរបស់សិស្សឲ្យបានកាន់តែច្រើន ជាពិសេស សំរាប់ក្រុមប្រជាជនដែលមិនសូវមានឱកាស និងក្រុមជួបការលំបាក។

២៧. ដោយសារកតិកាសញ្ញានេះទាមទារថា "លក្ខខណ្ឌសម្ភាររបស់គ្រូបង្រៀនត្រូវតែធ្វើឲ្យប្រសើរឡើងជាបណ្តើរៗ"។ តាមការអនុវត្តជាក់ស្តែង លក្ខខណ្ឌការងារទូទៅរបស់គ្រូបង្រៀនមានលក្ខណៈយ៉ាប់យ៉ឺនខ្លាំង ហើយបច្ចុប្បន្ន កំពុងស្ថិតនៅក្នុងស្ថានភាពទាបដែលមិនអាចទទួលយកបាននៅប្រទេសជាច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ស្ថានភាពនេះមិនត្រឹមតែមិនស្របតាមមាត្រា ១៣ (២) (e) ទេ ប៉ុន្តែឧបសគ្គដ៏ចំបងរារាំងដល់ការផ្តល់សិទ្ធិទទួលការអប់រំដល់កុមារឲ្យបានពេញលេញផងដែរ។ គណៈកម្មាធិការក៏កត់សំគាល់អំពីទំនាក់ទំនងរវាងមាត្រា ១៣ (២) (e) មាត្រា ២ (២) មាត្រា ៣ និងមាត្រា ៦–៨ នៃកតិកាសញ្ញានេះរាប់បញ្ចូលទាំងសិទ្ធិរបស់គ្រូបង្រៀនក្នុងការរៀបចំសមាគមផងដែរ។ គណៈកម្មាធិការក៏ទាញការចាប់អារម្មណ៍របស់រដ្ឋនានាឲ្យយកចិត្តទុកដាក់លើអនុសាសន៍រួមរបស់ UNESCO-ILO ស្តីពីឋានៈរបស់គ្រូបង្រៀន (១៩៦៦) និងអនុសាសន៍របស់ UNESCO និយាយអំពីឋានៈរបស់បុគ្គលិកបង្រៀននៅឧត្តមសិក្សា (១៩៩៧) ហើយជំរុញឲ្យប្រទេសទាំងអស់ធ្វើរបាយការណ៍អំពីវិធានការនានាដែលបានយកមកអនុវត្តដើម្បីធានាថាបុគ្គលិកបង្រៀនទាំងអស់ពិតជាទទួលបានលក្ខខណ្ឌនិងឋានៈសមស្របនឹងតួនាទីជាគ្រូបង្រៀន។

## មាត្រា ១៣ (៣) និង(៤) : សិទ្ធិទទួលបានសេរីភាពក្នុងការអប់រំ

២៨. មាត្រា ១៣ (៣) មានពីរផ្នែក ។ ផ្នែកមួយចែងថា គ្រប់រដ្ឋទាំងអស់ត្រូវតែគោរពសេរីភាពរបស់មាតាបិតា និងអាណាព្យាបាលដើម្បីធានាថា ការអប់រំសីលធម៌ និងសាសនាត្រូវស្របតាមឆន្ទៈតម្រូវការ និងជំនឿរបស់មាតាបិតា និងអាណាព្យាបាល។ ១៥/ គណៈកម្មាធិការយល់ឃើញថាផ្នែកនេះនៃមាត្រា ១៣ (៣) អនុញ្ញាតឲ្យបង្រៀននៅសាលារដ្ឋនៅក្នុងមុខវិជ្ជាប្រវត្តិវិទ្យានិយាយអំពីសាសនា និងសីលធម៌ ដោយមិនមានភាពលំអៀង ដោយគោរពសេរីភាពក្នុងការបញ្ចេញទស្សនៈសម្បជញ្ញៈ និងចំណាប់អារម្មណ៍។ គណៈកម្មាធិការក៏កត់សំគាល់ដែរថា ការអប់រំតាមសាលារដ្ឋដែលមានបង្រៀនអំពីសាសនា និងជំនឿគឺមិនស្របនឹងមាត្រា ១៣ (៣) បើបញ្ញត្តិមិនមានចែងអំពីការមិនរើសអើង ឬមិនមានមធ្យោបាយផ្សេងដែលបំរើបំណងរបស់មាតាបិតា និងអាណាព្យាបាលទេ។

២៩. ផ្នែកទី ២ នៃមាត្រា ១៣ (៣) និយាយអំពីសេរីភាពរបស់មាតាបិតា និងអាណាព្យាបាលក្នុងការជ្រើសរើសសាលាឲ្យកូនរៀនក្រៅពីសាលារដ្ឋ ឲ្យតែសាលារៀននោះឆ្លើយតបនឹង "ខ្នាតគំរូអប់រំអប្បបរមាដែលរដ្ឋបានកំណត់"។ លក្ខខណ្ឌនេះក៏មានចែងក្នុងបញ្ញត្តិបន្ថែមមាត្រា ១៣ (៤) ដែលចែងថា "សេរីភាពរបស់បុគ្គល ឬតំណាងគ្រប់រូបក្នុងការបង្កើត និងដឹកនាំស្ថាប័នអប់រំ"ឲ្យតែ

ស្ថាប័ននោះស្របតាមទិសដៅអប់រំដែលមានចែងក្នុងមាត្រា ១៣ (១) និងខ្នាតគំរូអប្បបរិមា។ ខ្នាតគំរូអប្បបរិមាអាចទាក់ទងនឹងបញ្ហា ដូចជា ឱកាសចូលរៀន កម្មវិធីសិក្សា និងការទទួលស្គាល់សញ្ញាប័ត្រ។ ខ្នាតគំរូនេះត្រូវស្របនឹងទិសដៅអប់រំដែលមានចែងក្នុងមាត្រា ១៣ (១)។

៣០. ក្រោមមាត្រា ១៣ (៤) មនុស្សគ្រប់រូប គិតទាំងជនបរទេស មានសេរីភាពក្នុងការបង្កើត និងដឹកនាំស្ថាប័នអប់រំ។ សេរីភាពក៏និយាយអំពី "បុគ្គល ឬតំណាង" ឱទហរណ៍ បុគ្គល ឬតំណាងស្របច្បាប់។ សេរីភាពគិតទាំងសិទ្ធិបង្កើត និងដឹកនាំស្ថាប័នអប់រំគ្រប់ប្រភេទ គិតទាំងទារកដ្ឋាន សាកលវិទ្យាល័យ និងស្ថាប័នអប់រំសំរាប់មនុស្សចាស់ផងដែរ។ ដោយសារមានគោលការណ៍មិនរើសអើង និងស្មើភាពគ្នា ព្រមទាំងការចូលរួមដ៏មានប្រសិទ្ធភាពក្នុងសង្គមសំរាប់ទាំងអស់គ្នា រដ្ឋត្រូវមានកាតព្វកិច្ចធានាថា សេរីភាពដែលមានចែងក្នុងមាត្រា ១៣ (៤) មិនបង្ហាញផ្លូវឈានទៅបង្កើតវិសមភាពគិតជាតួលេខខ្ពស់ក្នុងការអប់រំសំរាប់ក្រុមមនុស្សមួយចំនួននៅក្នុងសង្គមឡើយ។

## មាត្រា ១៣ : ប្រធានបទពិសេសនៃការអនុវត្តទូលំទូលាយ

### មិនរើសអើង និងការយកចិត្តទុកដាក់ស្មើៗគ្នា

៣១. ការហាមប្រាមមិនឲ្យមានការរើសអើងមានចែងនៅក្នុងមាត្រា ២(២) នៃកតិកាសញ្ញានេះទាក់ទងនឹងការសំរេចដោយវិជ្ជមាន ហើយក៏មានទាក់ទងនឹងការមានធនធានជារូបវ័ន្តផងដែរ។ មាត្រានេះមានវិសាលភាពគ្របលើគ្រប់ទិដ្ឋភាពអប់រំទាំងអស់ និងប្រមូលផ្តុំរាល់ឯកសារទាំងអស់ទាក់ទងនឹងការហាមប្រាមមិនឲ្យមានការរើសអើង។ គណៈកម្មាធិការបកប្រែមាត្រា ២ (២) និង(៣) ស្របតាមអនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការអប់រំ បញ្ញត្តិពាក់ព័ន្ធនៃអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីគ្រប់ទម្រង់ទាំងអស់ អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់ការរើសអើងជាតិសាសន៍គ្រប់ទម្រង់ទាំងអស់ អនុសញ្ញាស្តីពីសិទ្ធិកុមារ និង អនុសញ្ញា ILO ស្តីពីជនជាតិភាគតិច និងជនអន្តោរប្រាម ១៩៨៩ (អនុសញ្ញាលេខ ១៦៩) ហើយគណៈកម្មាធិការក៏មានបំណងយកចិត្តទុកដាក់លើបញ្ហាដូចខាងក្រោមផងដែរ។

៣២. ការអនុម័តវិធានការពិសេសជាបណ្តោះអាសន្នដែលមានបំណងនាំមកនូវសមភាព ឬភាពស្មើសិទ្ធិគ្នារវាងបុរស និងស្ត្រី និងសំរាប់ក្រុមមនុស្សដែលគ្មានឱកាស និងជួបការលំបាកមិនមែនជាការរំលោភសិទ្ធិ គ្មានការរើសអើងក្នុងការទទួលការអប់រំឡើយ លុះណា វិធានការទាំងនោះមិនបង្កលក្ខណៈឲ្យមានខ្នាតគំរូវិសមភាព ឬខ្នាតគំរូខុសគ្នាសំរាប់ក្រុមមនុស្សផ្សេងគ្នា ហើយលុះណាវិធានការទាំងនោះមិនអាចសំរេចគោលបំណងរបស់ខ្លួនបាន។

៣៣. ក្នុងករណីស្ថានភាពខ្លះ ប្រព័ន្ធអប់រំ ឬស្ថាប័នអប់រំដាច់ដោយឡែកសំរាប់ក្រុមមនុស្សផ្សេងគ្នាដូចមានកំណត់ប្រភេទនៅក្នុងមាត្រា ២ (២) នឹងជួយពីស្មារតីកតិកាសញ្ញានេះ។ ក្នុងករណីនេះគណៈកម្មាធិការប្រកាសច្បាស់ថា មាត្រា ២ នៃអនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការទទួលការអប់រំ (១៩៦០)។ ១៦/

៣៤. គណៈកម្មាធិការកត់សំគាល់មាត្រា ២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងមាត្រា ៣ (e) អនុសញ្ញា UNESCO ប្រឆាំងនឹងការរើសអើងក្នុងការទទួលការអប់រំ ហើយប្រកាសច្បាស់លាស់ថា គោលការណ៍មិនរើសអើងមានវិសាលភាពសំរាប់មនុស្សទាំងអស់ស្ថិតក្នុងវ័យរៀនសូត្ររស់នៅក្នុងប្រទេស គិតទាំងមនុស្សមិនមែនជនជាតិកំណើត ហើយមិនប្រកាន់ឋានៈស្របច្បាប់របស់មនុស្សទាំងនោះឡើយ។

៣៥. វិសមភាពគិតជាតួលេខខ្ពស់នៅក្នុងគោលនយោបាយដែលធ្វើឲ្យខុសគុណភាពអប់រំសំរាប់ក្រុមមនុស្សផ្សេងៗគ្នាដែលរស់នៅក្នុងតំបន់ភូមិសាស្ត្រខុសគ្នាអាចជំរុញឲ្យមានការរើសអើងនៅក្រោមកតិកាសញ្ញានេះ។

៣៦. គណៈកម្មាធិការប្រកាសអះអាងច្បាស់ចំពោះកថាខ័ណ្ឌ ៣៥ នៃយោបល់ទូទៅលេខ ៥ ដែលឆ្លើយតបនឹងតម្រូវការរបស់មនុស្សពិការ ស្របតាមស្មារតីសិទ្ធិទទួលការអប់រំ និងកថាខ័ណ្ឌ ៣៦–៤២ នៃយោបល់ទូទៅលេខ ៦ ដែលឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់ទាក់ទងនឹងមាត្រា ១៣ – ១៥ នៃកតិកាសញ្ញានេះ។

៣៧. ប្រទេសទាំងអស់ត្រូវតាមដាន ត្រួតពិនិត្យឲ្យបានដិតដល់លើការអប់រំ – គិតទាំងគោលនយោបាយពាក់ព័ន្ធ ស្ថាប័នពាក់ព័ន្ធ កម្មវិធី បែបបទចំណាយ និងការអនុវត្តផ្សេងៗទៀតក្នុងគោលបំណងរិះរកវិធានការ និងចាត់វិធានការដើម្បីកាត់បន្ថយការរើសអើង។ ទិន្នន័យអប់រំត្រូវបំបែកតាមប្រភេទឲ្យច្បាស់លាស់ដោយមិនមានបង្ហាញអំពីការរើសអើង។

### ***សេរីភាពបណ្ឌិតសភា និងស្វ័យភាពស្ថាប័ន ១៧/***

៣៨. តាមការសិក្សាវិភាគរបាយការណ៍របស់ប្រទេសនានាជាច្រើន គណៈកម្មាធិការយល់ឃើញថា សិទ្ធិទទួលការអប់រំអាចសំរេចបាន លុះណាបុគ្គលិក និងនិស្សិតមានសេរីភាពសិក្សា។ ដូចនេះ ទោះបញ្ហានេះមិនមានបញ្ជាក់ច្បាស់នៅក្នុងមាត្រា ១៣ ក៏ដោយ ក៏ប៉ុន្តែសមស្រប និងចាំបាច់សំរាប់គណៈកម្មាធិការធ្វើការអង្កេតអំពីសេរីភាពសិក្សាបានដែរ។ ចំណាប់អារម្មណ៍មួយចំនួនយកចិត្តទុកដាក់ ជាពិសេសលើការអប់រំឧត្តមសិក្សា ព្រោះបើតាមបទពិសោធន៍របស់គណៈកម្មាធិការ បុគ្គលិក និងនិស្សិតនៅតាមឧត្តមសិក្សាគឺងាយរងគ្រោះដោយសារសម្ពាធនយោបាយ និងសម្ពាធផ្សេងទៀតដែលជាកត្តាកំណត់សេរីភាពសិក្សា។ គណៈកម្មាធិការមានចំណាប់អារម្មណ៍យ៉ាងពិសេសថា បុគ្គលិក និងនិស្សិតនៅក្នុងវិស័យអប់រំមានសិទ្ធិទទួលសេរីភាពសិក្សា ហើយការអង្កេតជាច្រើនខាងក្រោមអាចអនុវត្តបានជាទូទៅនៅគ្រប់ស្ថានភាព។

៣៩. សមាជិកសហគមន៍អ្នកសិក្សា ជាបុគ្គល និងជារួម មានសេរីភាពអនុវត្ត អភិវឌ្ឍ និងផ្ទេរចំណេះដឹង និងគំនិតរបស់ខ្លួនតាមរយៈការស្រាវជ្រាវ បង្រៀន រៀន ពិភាក្សា តាមរយៈឯកសារ ផលិតកម្ម ការច្នៃប្រឌិត ឬការសរសេរ។ សេរីភាពសិក្សារួមមានសេរីភាពរបស់បុគ្គលក្នុងការបញ្ចេញ

ទស្សនៈដោយសេរីអំពីស្ថាប័ន ឬអំពីប្រព័ន្ធដែលសមាជិកទាំងនោះធ្វើការ មានសេរីភាពក្នុងការបំពេញមុខងាររបស់ខ្លួនដោយគ្មានការរើសអើង ឬដោយគ្មានខ្លាចការបង្ក្រាបដោយរដ្ឋាភិបាល ឬដោយអ្នកផ្សេងទៀត សេរីភាពក្នុងការចូលរួមក្នុងអង្គការ សមាគមជំនាញ និងសេរីភាពទទួលសិទ្ធិមនុស្សទាំងអស់ដែលទទួលស្គាល់ជាអន្តរជាតិ ស្របតាមតម្រូវការជាក់ស្តែងរបស់បុគ្គលក្នុងក្របខ័ណ្ឌច្បាប់ដូចគ្នា។ ការទទួលបានសេរីភាពសិក្សា ដូចជា ភារកិច្ចគោរពសេរីភាពសិក្សារបស់អ្នកដទៃដើម្បីធានាឲ្យមានការពិភាក្សាដោយត្រឹមត្រូវអំពីទស្សនៈទានផ្ទុយគ្នា គោរព និងយកចិត្តទុកដាក់ចំពោះមនុស្សទាំងអស់ដោយគ្មានការរើសអើងដោយសំអាងលើលក្ខខណ្ឌច្បាស់លាស់។

៤០. ការទទួលបានសេរីភាពសិក្សាទាមទារឲ្យមានស្វ័យភាពរបស់ស្ថាប័នឧត្តមសិក្សា ។ ស្វ័យភាពគឺនិយាយអំពីកំរិតអភិបាលកិច្ចស្វយ័តចាំបាច់សំរាប់ចេញសេចក្តីសំរេចដែលមានប្រសិទ្ធភាពរបស់ស្ថាប័នឧត្តមសិក្សាទាក់ទងនឹងការងារបណ្ឌិតសភា ខ្នាតគំរូ ការគ្រប់គ្រង និងសកម្មភាពទាក់ទងផ្សេងៗទៀតរបស់ស្ថាប័នឧត្តមសិក្សា។ អភិបាលកិច្ចស្វយ័តត្រូវតែស្របតាមប្រព័ន្ធគណនេយ្យភាពសាធារណៈ ជាពិសេសទាក់ទងនឹងមូលនិធិឧបត្ថម្ភដោយរដ្ឋាភិបាល។ ដោយសារមានវិនិយោគរបស់រដ្ឋច្រើនសំរាប់ឧត្តមសិក្សា តុល្យភាពសមស្របត្រូវតែថ្លឹងថ្លែងរវាងស្វ័យភាព ស្ថាប័ន និងគណនេយ្យភាព។ ដោយសារគ្មានគំរូណាមួយអាចយកមកអនុវត្តតាមបាន ការចាត់ចែងស្ថាប័នឧត្តមសិក្សាត្រូវតែមានលក្ខណៈត្រឹមត្រូវ យុត្តិធម៌ និងសមធម៌ មានតម្លាភាព និងមានការចូលរួមកាន់តែច្រើនពីគ្រប់ភាគីពាក់ព័ន្ធ។

***វិន័យសាលា ១៨)***

៤១. តាមទស្សនៈរបស់គណៈកម្មាធិការ ការដាក់ទណ្ឌកម្មលើរាងកាយគឺផ្ទុយគ្នានឹងគោលការណ៍គ្រឹះនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងនៅក្នុងលំនាំដើមនៃសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាទាំងពីរ : សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ១៩/ លក្ខខណ្ឌផ្សេងៗនៃវិន័យសាលាប្រហែលជាអាចផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដូចជា ការបង្អាប់មុខ ឬ ធ្វើឲ្យខ្មាសគេកណ្តាលចំណោម។ មិនមានវិន័យមួយណាដែលមិនផ្ទុយនឹងសិទ្ធិផ្សេងៗដែលមានចែងនៅក្នុងកតិកាសញ្ញានេះទេ ដូចជា សិទ្ធិមានម្ហូបបរិភោគ។ រដ្ឋាភិបាលត្រូវតែចាត់វិធានការដើម្បីធានាថាវិន័យសាលាដែលផ្ទុយនឹងស្មារតីនៃកតិកាសញ្ញានេះមិនត្រូវកើតឡើងនៅក្នុងស្ថាប័នអប់រំរដ្ឋ ឬឯកជនឡើយក្នុងលក្ខខណ្ឌច្បាប់របស់ខ្លួន។ គណៈកម្មាធិការសូមស្វាគមន៍គំនិតផ្តួចផ្តើម និងសកម្មភាពដែលរដ្ឋាភិបាលនានាបំផុស និងជំរុញឲ្យសាលាចាប់ផ្តើមអនុវត្តវិធីគ្មានហិង្សាប្រកបដោយលក្ខណៈវិជ្ជមានទៅលើវិន័យសាលា។

### ភាពខ្វះខាតរបស់មាត្រា ១៣

៤២. គណៈកម្មាធិការមានបំណងបញ្ជាក់ថា ភាពខ្វះខាតរបស់កតិកាសញ្ញានៅមាត្រា ៤ ជាដំបូងមានបំណងការពារសិទ្ធិរបស់មនុស្សគ្រប់រូបជាជាងអនុញ្ញាតឲ្យរដ្ឋាភិបាលបង្ខំពលរដ្ឋ។ ដូចនេះ រដ្ឋាភិបាលដែលបិទសាកលវិទ្យាល័យ ឬស្ថាប័នអប់រំណាមួយដោយឈរលើមូលហេតុសន្តិសុខ ឬរក្សាសណ្តាប់ធ្នាប់សង្គមត្រូវមានកាតព្វកិច្ចពន្យល់អំពីវិធានការតឹងរឹងបែបនេះតាមចំណុចនីមួយៗនៅក្នុងមាត្រា ៤។

## II. កាតព្វកិច្ចរបស់រដ្ឋាភិបាល និងការរំលោភបំពាន

### កាតព្វកិច្ចស្របច្បាប់ទូទៅ

៤៣. ដោយសារកតិកាសញ្ញានេះផ្តល់នូវការរីកចំរើនក្នុងការសំរេចសិទ្ធិទទួលការអប់រំ និងទទួលស្គាល់ការលំបាកដោយសារកង្វះខាតធនធាន កតិកាសញ្ញានេះត្រូវបង្ខំឲ្យរដ្ឋាភិបាលទទួលកាតព្វកិច្ចជាច្រើនដែលត្រូវអនុវត្តជាបន្ទាន់។ ២០/ រដ្ឋាភិបាលមានកាតព្វកិច្ចបន្ទាន់ទាក់ទងនឹងសិទ្ធិទទួលការអប់រំ ដូចជា "ធានា" ថា "សិទ្ធិនេះនឹងត្រូវទទួលដោយគ្មានការរើសអើងក្នុងគ្រប់ទម្រង់ទាំងអស់" មាត្រា (២ (២)) ហើយកាតព្វកិច្ច "ត្រូវចាត់វិធានការអនុវត្ត" (មាត្រា ២ (១)) ដើម្បីធានា សំរេចទិសដៅរបស់មាត្រា ១៣ ទាំងស្រុង។ ២១/ វិធានការទាំងនេះត្រូវមានលក្ខណៈ "បំរុងទុក ជាមុនច្បាស់លាស់ និងមានទិសដៅត្រឹមត្រូវ" ដើម្បីឈានទៅសំរេចសិទ្ធិទទួលការអប់រំដោយ ពេញលេញ។

៤៤. ការសំរេចសិទ្ធិទទួលការអប់រំជាបន្តបន្ទាប់មានន័យថា "រីកចំរើនជាបណ្តើរៗ"មិនគួរបកប្រែថាជាការផ្អាក ឬបង្អាក់កាតព្វកិច្ចរបស់រដ្ឋាភិបាលដែលមានចែងអត្ថន័យពេញលេញនោះទេ។ ការសំរេចជាបណ្តើរៗមានន័យថា រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចជាក់លាក់ និងបន្តបន្ទាប់"ដើម្បីឈានទៅសំរេចមាត្រា ១៣ ឲ្យបានពេញលេញ យ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។ (២២)

៤៥. មានការសន្មតិទុកជាមុនមួយទៅលើការមិនអនុញ្ញាតឲ្យចាត់វិធានការដើរថយក្រោយក្នុងការសំរេចសិទ្ធិទទួលការអប់រំ និងការសំរេចសិទ្ធិផ្សេងៗទៀត ដែលមានចែងនៅក្នុងកតិកាសញ្ញានេះ។ បើចាត់វិធានការដើរថយក្រោយមែន រដ្ឋាភិបាលត្រូវមានភារកិច្ចបញ្ជាក់ថា វិធានការដើរថយក្រោយនេះត្រូវបានប្រើប្រាស់ក្រោយពីពិចារណាគ្រប់ជ្រុងជ្រោយលើវិធានការផ្សេងៗរួចហើយ ព្រមទាំងបញ្ជាក់ថា វិធានការទាំងនេះត្រូវបានពន្យល់លំអិត ច្បាស់លាស់ដោយយោងលើសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញា និងដោយយោងលើការប្រើប្រាស់ធនធានរបស់រដ្ឋាភិបាលដល់កំរិតអតិបរមា។ (២៣)

៤៦. សិទ្ធិទទួលការអប់រំ ដូចសិទ្ធិមនុស្សទាំងអស់ដែរ បង្ខំឲ្យរដ្ឋាភិបាលអនុវត្តកាតព្វកិច្ចបីប្រភេទ និងបីកំរិតគឺ : កាតព្វកិច្ចគោរពសិទ្ធិ ការពារសិទ្ធិ និងបំពេញសិទ្ធិ។ កាតព្វកិច្ចបំពេញសិទ្ធិមានបញ្ចូលកាតព្វកិច្ចពីរទៀតគឺ កាតព្វកិច្ចសំរបសំរួលសិទ្ធិ និងកាតព្វកិច្ចផ្តល់សិទ្ធិ។

៤៧. កាតព្វកិច្ចគោរពសិទ្ធិតម្រូវឲ្យរដ្ឋាភិបាលចៀសវាងមិនប្រើវិធានការដែលហាមប្រាម ឬទប់ស្កាត់មិនឲ្យពលរដ្ឋទទួលបានសិទ្ធិទទួលការអប់រំ ។ កាតព្វកិច្ចការពារសិទ្ធិតម្រូវឲ្យរដ្ឋាភិបាលចាត់វិធានការដែលការពារភាគីទីបីកុំឲ្យមានការយារយី និងរំខានក្នុងការទទួលសិទ្ធិទទួលការអប់រំ។ កាតព្វកិច្ចបំពេញសិទ្ធិ (សំរបសំរួល) ទាមទារឲ្យរដ្ឋាភិបាលចាត់វិធានការវិជ្ជមានដែលធានា និងជួយពលរដ្ឋ និងសហគមន៍ឲ្យទទួលបានសិទ្ធិទទួលការអប់រំ។ ជាទីបញ្ចប់ រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចមួយទៀតគឺបំពេញសិទ្ធិ (ផ្តល់សិទ្ធិ) ទទួលការអប់រំ។ តាមច្បាប់ទូទៅមួយ រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបំពេញសិទ្ធិជាក់លាក់ណាមួយ (ផ្តល់សិទ្ធិណាមួយ) ដែលមានចែងនៅក្នុងកតិកាសញ្ញា បើពលរដ្ឋណាម្នាក់ ឬមនុស្សមួយក្រុមណាមិនមានសមត្ថភាពទទួលសិទ្ធិ ដោយសារហេតុផលដែលគេមិនអាចគ្រប់គ្រងបានតាមមធ្យោបាយដែលអាចអនុវត្តបាន។ ប៉ុន្តែវិសាលភាពនៃកាតព្វកិច្ចនេះគឺទាក់ទងនឹងស្មារតីនៃកតិកាសញ្ញានេះ។

៤៨. ក្នុងករណីនេះ ចំណុចសំខាន់២នៅក្នុងមាត្រា១៣ ត្រូវយកចិត្តទុកដាក់ជាចាំបាច់។ ចំណុចទី១ ពន្យល់ច្បាស់ថា មាត្រា ១៣ ឲ្យរដ្ឋាភិបាលទទួលខុសត្រូវជាសំខាន់ក្នុងការផ្តល់ការអប់រំដោយផ្ទាល់ក្នុងគ្រប់ស្ថានភាពទាំងអស់។ រដ្ឋាភិបាលទទួលស្គាល់ថា "ការអភិវឌ្ឍន៍ប្រព័ន្ធសាលារៀននៅគ្រប់កំរិតត្រូវតែអនុវត្តឲ្យសកម្ម" (មាត្រា ១៣ (២) (e))។ ចំណុចទី ២ ដោយសារការប្រើពាក្យខុសគ្នានៅក្នុងមាត្រា ១៣ (២) ទាក់ទងនឹងអប់រំបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះ កត្តាកំណត់កាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការបំពេញសិទ្ធិ (ផ្តល់សិទ្ធិ) គឺមិនដូចគ្នានៅគ្រប់កំរិតអប់រំទាំងអស់នោះទេ។ ដូចនេះ យោងតាមស្មារតីនៃខ្លឹមសារអត្ថបទរបស់កតិកាសញ្ញា រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបន្ថែមទៀតក្នុងការបំពេញសិទ្ធិ (ផ្តល់សិទ្ធិ) ទទួលការអប់រំ ប៉ុន្តែវិសាលភាពនៃកាតព្វកិច្ចនេះមិនស្របគ្នានៅគ្រប់កំរិតអប់រំទាំងអស់ទេ។ គណៈកម្មាធិការអង្កេតឃើញថាការបកប្រែកាតព្វកិច្ចបំពេញសិទ្ធិ (ផ្តល់សិទ្ធិ) តាមមាត្រា ១៣ ត្រូវស្របតាមច្បាប់ និងតាមការអនុវត្តរបស់រដ្ឋាភិបាលជាច្រើន។

## កាតព្វកិច្ចស្របច្បាប់ជាក់លាក់

៤៩. រដ្ឋាភិបាលត្រូវធានាថា កម្មវិធីសិក្សាសំរាប់គ្រប់កំរិតសិក្សាទាំងអស់ត្រូវរួមចំណែកក្នុងការសំរេចទិសដៅដូចមានចែងក្នុងមាត្រា ១៣ (១)។ ២៤/ រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបង្កើត និងរក្សាប្រព័ន្ធអប់រំឲ្យមានតម្លាភាព និងមានប្រសិទ្ធភាព ដែលប្រព័ន្ធនេះអាចតាមដាន ត្រួតពិនិត្យថាតើការអប់រំឈានទៅសំរេចទិសដៅអប់រំដែលមានចែងនៅក្នុងមាត្រា ១៣ (១) ឬ យ៉ាងណា។

៥០. ទាក់ទងនឹងមាត្រា ១៣ (២) រដ្ឋាភិបាលមានកាតព្វកិច្ចគោរព ការពារ និងបំពេញសិទ្ធិតាម "លក្ខខណ្ឌចាំបាច់នីមួយៗ"គឺ (មានធនធានរូបវ័ន្ត មានឱកាសចូលរៀន អាចទទួលយកបាន និងអាចកែសំរួលឲ្យស្របតាមតម្រូវការជាក់ស្តែង) នៃសិទ្ធិទទួលការអប់រំ។ តាមការបង្ហាញឲ្យឃើញរូបរាងជាក់ស្តែង រដ្ឋាភិបាលត្រូវធានាឲ្យមានធនធានរូបវ័ន្តសំរាប់ការអប់រំដោយមិនបិទសាលាឯកជន ការពារឱកាសចូលរៀនដោយធានាថា ភាគីទីបីគិតទាំងមាតាបិតា និងនិយោជកមិនបញ្ឈប់ក្មេងស្រីពីការសិក្សានៅសាលា បំពេញសិទ្ធិ (សំរបសំរួលសិទ្ធិ) ក្នុងការទទួលយកការអប់រំដោយចាត់វិធានការវិជ្ជមានដើម្បីធានាថា ការអប់រំត្រូវតែសមស្របតាមលក្ខណៈវប្បធម៌សំរាប់ជនជាតិភាគតិច និងជនអន្តោគ្រាម និងមានគុណភាពសំរាប់ទាំងអស់គ្នា បំពេញសិទ្ធិ (ផ្តល់សិទ្ធិ) ក្នុងការកែសំរួលការអប់រំឲ្យស្របតាមតម្រូវការជាក់ស្តែងដោយផ្តល់ធនធានសំរាប់រៀបរៀងកម្មវិធីសិក្សាដែលឆ្លុះបញ្ចាំងអំពីតម្រូវការជាក់ស្តែងរបស់សិស្សដែលរស់នៅក្នុងពិភពលោកដែលពោរពេញដោយការប្រែប្រួល និងបំពេញសិទ្ធិ (ផ្តល់សិទ្ធិ) ក្នុងការធានាឲ្យការអប់រំមានធនធានរូបវ័ន្ត ដោយអភិវឌ្ឍប្រព័ន្ធសាលារៀន គិតទាំងសំណង់បន្ទប់រៀន កម្មវិធីផ្តល់ការអប់រំផ្តល់ឯកសាររៀន–បង្រៀន និងផ្តល់ប្រាក់ខែដល់គ្រូបង្រៀនតាមលក្ខណៈប្រកួតប្រជែងក្នុងស្រុក។

៥១. ដូចបានអង្កេតរួចហើយ កាតព្វកិច្ចរបស់រដ្ឋាភិបាលទាក់ទងនឹងការអប់រំបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះមិនអាចខុសគ្នាបានទេ។ ដោយសារពាក្យប្រើប្រាស់នៅក្នុងមាត្រា ១៣ (២) រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចកំណត់អាទិភាពនៃការចាប់ផ្តើមអនុវត្តការអប់រំបឋមសិក្សាដោយកាតព្វកិច្ច ដោយឥតបង់ថ្លៃ។ ២៥/ ការបកប្រែមាត្រា ១៣ (២) ត្រូវបានអនុវត្តតាមអាទិភាពដែលបានកំណត់ ស្របតាមអប់រំបឋមសិក្សាក្នុងមាត្រា ១៤។ កាតព្វកិច្ចផ្តល់ការអប់រំបឋមសិក្សាសំរាប់ទាំងអស់គ្នាជាភារកិច្ចបន្ទាន់មួយរបស់គ្រប់រដ្ឋទាំងអស់។

៥២. ទាក់ទងនឹងមាត្រា ១៣ (២)(b)–(d) រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបន្ទាន់មួយ "ចាត់វិធានការ" (មាត្រា ២ (១)) ឈានទៅសំរេចអប់រំមធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះសំរាប់ទាំងអស់គ្នាតាមក្របខ័ណ្ឌច្បាប់របស់ខ្លួន។ ក្នុងកំរិតអប្បបរមា រដ្ឋាភិបាលត្រូវអនុម័ត និងអនុវត្តយុទ្ធសាស្ត្រអប់រំជាតិដែលរួមមានការផ្តល់ការអប់រំមធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះឲ្យស្របតាមស្មារតីនៃកតិកាសញ្ញានេះ។ យុទ្ធសាស្ត្រនេះរួមមានយន្តការ ដូចជា សូចនាករណ៍ និងទិសដៅកំណត់ស្តីពីសិទ្ធិទទួលការអប់រំដែលងាយស្រួលសំរាប់តាមដាន ត្រួតពិនិត្យការរីកចំរើនក្នុងវិស័យអប់រំ។

៥៣. ក្រោមមាត្រា ១៣(២)(e) រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចធានាថា ប្រព័ន្ធអាហារូបករណ៍អប់រំត្រូវបង្កើតឡើងដើម្បីជួយដល់ក្រុមប្រជាជនដែលមិនសូវមានឬមិនមានឱកាសឬក្រុមប្រជាជនជួបការលំបាក។ ២៦/ កាតព្វកិច្ចអនុវត្តយ៉ាងសកម្មដើម្បី "អភិវឌ្ឍប្រព័ន្ធសាលារៀននៅគ្រប់កំរិត" ជំរុញឲ្យរដ្ឋាភិបាលទទួលខុសត្រូវដើម្បីធានាផ្តល់សិទ្ធិទទួលការអប់រំក្នុងគ្រប់ស្ថានភាពទាំងអស់។ (២៧)

៥៤. រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចបង្កើត"ខ្នាតគំរូអប់រំអប្បបរមា" ដែលស្ថាប័នអប់រំទាំងអស់ត្រូវបង្កើតឡើងស្របតាមមាត្រា ១៣ (៣) និង(៤)។ រដ្ឋាភិបាលត្រូវរក្សាប្រព័ន្ធមួយដែលមានតម្លាភាព និងមានប្រសិទ្ធភាពដើម្បីតាមដាន ត្រួតពិនិត្យការសំរេចខ្នាតគំរូទាំងនេះ។ រដ្ឋាភិបាលមិនមានកាតព្វកិច្ចផ្តល់មូលនិធិឲ្យស្ថាប័នដែលបង្កើតឡើងស្របតាមមាត្រា ១៣ (៣) និង(៤) ទេ ប៉ុន្តែបើរដ្ឋាភិបាលជ្រើសរើសផ្លូវមួយផ្តល់ហិរញ្ញវត្ថុឲ្យទៅស្ថាប័នអប់រំឯកជនបែបនេះ រដ្ឋាភិបាលនោះត្រូវធ្វើយ៉ាងណាចៀសវាងផ្តល់មូលនិធិដោយមានការរើសអើងឲ្យស្របតាមច្បាប់។

៥៥. រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចមួយធានាថា សហគមន៍ និងគ្រួសារមិនពឹងពាក់លើពលកម្មកុមារឡើយ។ គណៈកម្មាធិការបញ្ជាក់ជាពិសេសអំពីសារៈសំខាន់នៃការអប់រំក្នុងការលុបបំបាត់ពលកម្មកុមារ ហើយមានកាតព្វកិច្ចជាច្រើនទៀត ដូចមានចែងក្នុងមាត្រា ៧ (២) នៃអនុសញ្ញាអំពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ១៩៩៩ (អនុសញ្ញាលេខ ១៨២)។ ២៨/ លើសនេះទៀត ដោយសារមានមាត្រា ២ (២) រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចលុបបំបាត់ទំលាប់មិនល្អ និងការយល់ខុសអំពីយេនឌ័រដែលជាឧបសគ្គរារាំងដល់ឱកាសចូលរៀនរបស់កុមារី របស់ស្ត្រី និងរបស់ក្រុមប្រជាជនដែលមិនសូវមាន ឬ មិនមានឱកាស ឬក្រុមប្រជាជនជួបការលំបាក។

៥៦. នៅក្នុងយោបល់ទូទៅលេខ ៣ គណៈកម្មាធិការទាញការចាប់អារម្មណ៍ទៅលើកាតព្វកិច្ចរបស់រដ្ឋាភិបាលទាំងអស់ក្នុងការចាត់វិធានការ"តាមប្រទេស និងតាមរយៈជំនួយអន្តរជាតិ និងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស" ដើម្បីឈានទៅសំរេចការផ្តល់សិទ្ធិឲ្យបានពេញលេញដូចមានចែងនៅក្នុងកតិកាសញ្ញា ដូចជា សិទ្ធិទទួលការអប់រំ។ ២៩/ មាត្រា ២ (១) និងមាត្រា ២៣ នៃអនុសញ្ញា មាត្រា ៥៦ នៃធម្មនុញ្ញសហប្រជាជាតិ មាត្រា ១០ នៃសេចក្តីថ្លែងការណ៍សកលលោកស្តីពីអប់រំសំរាប់ទាំងអស់គ្នា និងផ្នែកទី ១ កថាខ័ណ្ឌ ៣៤ នៃសេចក្តីថ្លែងការណ៍ និងកម្មវិធីសកម្មភាពក្រុងវេនីសជំរុញឲ្យរដ្ឋាភិបាលទទួលកាតព្វកិច្ចទាក់ទងនឹងការផ្តល់ជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីសំរេចសិទ្ធិទទួលការអប់រំឲ្យបានពេញលេញ។ ទាក់ទងនឹងការចរចា និងការចេញសច្ចាប័នលើកិច្ចព្រមព្រៀងអន្តរជាតិ រដ្ឋាភិបាលត្រូវចាត់វិធានការដើម្បីធានាថា ច្បាប់ និងកិច្ចព្រមព្រៀងទាំងនេះមិនមានឥទ្ធិពលអាក្រក់ទៅលើសិទ្ធិទទួលការអប់រំឡើយ។ ដូចគ្នានេះដែរ រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចមួយដើម្បីធានាថា រាល់សកម្មភាពទាំងអស់ ជាសមាជិកនៃអង្គការអន្តរជាតិ គិតទាំងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិត្រូវទទួលខុសត្រូវចំពោះការផ្តល់សិទ្ធិទទួលការអប់រំឲ្យបាន។

៥៧. នៅក្នុងយោបល់ទូទៅលេខ ៣ គណៈកម្មាធិការបញ្ជាក់ច្បាស់ថា រដ្ឋាភិបាលត្រូវមាន "កាតព្វកិច្ចស្នូលអប្បបរមាមួយដើម្បីធានា យ៉ាងហោចណាស់ សំរេចឲ្យបានកំរិតអប្បបរមា" នៃសិទ្ធិនីមួយៗ ដែលមានចែងនៅក្នុងកតិកាសញ្ញា គិតទាំង "ទម្រង់អប់រំមូលដ្ឋានបំផុត"។ ក្នុងបរិបទមាត្រា ១៣ កាតព្វកិច្ចស្នូលនេះមានកាតព្វកិច្ចមួយគឺ : ធានាផ្តល់សិទ្ធិទទួលការអប់រំនៅតាមស្ថាប័ន និងកម្មវិធីអប់រំរដ្ឋដោយគ្មានការរើសអើង ធានាថា ការអប់រំត្រូវស្របតាមទិសដៅអប់រំដែលមាន

ចែងនៅក្នុងមាត្រា ១៣ (១) ផ្តល់ការអប់រំបឋមសិក្សាសំរាប់ទាំងអស់គ្នាឲ្យស្របតាមមាត្រា ១៣ (២) (a) អនុម័ត និងអនុវត្តយុទ្ធសាស្ត្រអប់រំជាតិ ដែលផ្តល់ការអប់រំនៅមធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះ ហើយធានាផ្តល់ការអប់រំក្នុងជំរើសដោយសេរីដោយគ្មានការរំខាន ឬ យាយីពីសំណាក់រដ្ឋាភិបាល ឬភាគីទីបីឡើយ ដោយស្របតាម"ខ្នាតគំរូអប់រំអប្បបរមា" មាត្រា ១៣ (៣) និង(៤))។

**ការរំលោភបំពាន**

៥៨. នៅពេលដែលខ្លឹមសារនៃមាត្រា ១៣ (ផ្នែកទី I) ត្រូវបានអនុវត្តស្របតាមកាតព្វកិច្ចទូទៅ និងកាតព្វកិច្ចជាក់លាក់របស់រដ្ឋាភិបាល (ផ្នែកទី II) សកម្មភាពមួយត្រូវបានអនុវត្តក្នុងចលនាជួយកំណត់រកអត្តសញ្ញាញនៃការរំលោភបំពានលើសិទ្ធិទទួលការអប់រំ។ ការរំលោភបំពានលើមាត្រា ១៣ អាចកើតឡើងតាមរយៈសកម្មភាពផ្ទាល់របស់រដ្ឋាភិបាល (ទង្វើរបស់គណៈកម្មាធិការ) ឬតាមរយៈការមិនចាត់វិធានការនានា ដូចមានចែងនៅក្នុងកតិកាសញ្ញា (ទង្វើនៃការលុបចោល)។

៥៩. ដោយបង្ហាញរូបភាពច្បាស់លាស់ ការរំលោភបំពានលើមាត្រា ១៣ រួមមាន : ការចាប់ផ្តើមអនុវត្ត ឬការមិនលុបចោលច្បាប់ដែលរើសអើងប្រឆាំងនឹងបុគ្គល ឬក្រុមមនុស្សតាមការហាមប្រាមនៅក្នុងច្បាប់ក្នុងវិស័យអប់រំ ការមិនចាត់វិធានការដែលអាចដោះស្រាយបញ្ហានៃការរើសអើងនៅក្នុងវិស័យអប់រំ ការប្រើប្រាស់កម្មវិធីសិក្សាដែលមិនស្របតាមទិសដៅអប់រំដែលមានចែងនៅក្នុងមាត្រា ១៣ (១) ការមិនរក្សាប្រព័ន្ធអប់រំឲ្យមានតម្លាភាព និងមានប្រសិទ្ធភាពសំរាប់តាមដានត្រួតពិនិត្យឲ្យស្របតាមមាត្រា ១៣ (១) ដោយសារបញ្ហាអាទិភាព មិនចាប់ផ្តើមអនុវត្តអប់រំបឋមសិក្សាដោយកាតព្វកិច្ច និងដោយឥតបង់ថ្លៃសំរាប់ទាំងអស់គ្នា ការមិនចាត់វិធានការ "បំរុងទុក ច្បាស់លាស់ និងមានទិសដៅច្បាស់លាស់" ដើម្បីសំរេចការរីកចំរើនផ្នែកអប់រំមធ្យមសិក្សា ឧត្តមសិក្សា និងអប់រំគ្រឹះជាបណ្តើរៗឲ្យស្របតាមមាត្រា ១៣ (២) (b) – (d) ហាមប្រាមស្ថាប័នអប់រំឯកជន មិនធានាឲ្យស្ថាប័នអប់រំឯកជនអនុវត្តស្របតាម"ខ្នាតគំរូអប់រំអប្បបរមា" កំណត់នៅក្នុងមាត្រា ១៣ (៣) និង(៤) បដិសេធមិនឲ្យមានសេរីភាពសិក្សារបស់បុគ្គលិក និងនិស្សិត បិទស្ថាប័នអប់រំក្នុងពេលមានវិបត្តិនយោបាយផ្ទុយនឹងមាត្រា ៤។

## III. កាតព្វកិច្ចរបស់អ្នកអនុវត្ត ជាជាងកាតព្វកិច្ចរបស់រដ្ឋាភិបាល

៦០. តាមមាត្រា ២២ នៃកតិកាសញ្ញា តួនាទីរបស់ទីភ្នាក់ងារសហប្រជាជាតិ គិតទាំងតួនាទីនៅតាមប្រទេស តាមរយៈក្របខ័ណ្ឌសកម្មភាពជំនួយអភិវឌ្ឍន៍សហប្រជាជាតិ (UNDAF) មានសារៈសំខាន់ជាពិសេសទាក់ទងនឹងការសំរេចគោលដៅមាត្រា ១៣។ កិច្ចប្រឹងប្រែងដើម្បីសំរេចសិទ្ធិទទួលការអប់រំនឹងត្រូវលើកកំពស់ទំនាក់ទំនង និងអន្តរទំនាក់ទំនងក្នុងចំណោមអ្នកអនុវត្តពាក់ព័ន្ធទាំងអស់ គិតទាំងសង្គមស៊ីវិលផងដែរ។ UNESCO UNDP UNICEF ILO ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍តំបន់ មូលនិធិរូបិយវត្ថុអន្តរជាតិ និងអង្គការពាក់ព័ន្ធផ្សេង

ទៀតនៅក្នុងប្រព័ន្ធសហប្រជាជាតិគួរលើកកំពស់កិច្ចសហប្រតិបត្តិការសំរាប់អនុវត្តការផ្តល់សិទ្ធិទទួលការអប់រំនៅតាមប្រទេសដោយគោរពតាមអាណត្តិទទួលខុសត្រូវរបស់ប្រទេស និងគោរពតាមជំនាញដែលមានស្រាប់នៅក្នុងប្រទេស។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ជាពិសេសធនាគារពិភពលោក និងមូលនិធិហិរញ្ញវត្ថុអន្តរជាតិគួរយកចិត្តទុកដាក់ការពារសិទ្ធិទទួលការអប់រំនៅក្នុងគោលនយោបាយកម្ចីឥណទាន កិច្ចព្រមព្រៀងឥណទាន កម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ និងវិធានការដោះស្រាយវិបត្តិបំណុល។ ៣០/ នៅពេលវិភាគរបាយការណ៍របស់ប្រទេសនានា គណៈកម្មាធិការនឹងពិចារណាលើផលចំណេញបានពីជំនួយដែលផ្តល់ដោយអ្នកអនុវត្តទាំងអស់ជាជាងជំនួយបានពីរដ្ឋាភិបាលលើសមត្ថភាពរបស់រដ្ឋក្នុងការបំពេញកាតព្វកិច្ចនានាដូចមានចែងនៅក្នុងមាត្រា ១៣។ ការអនុម័តវិធីដោះស្រាយបញ្ហាឈរលើសិទ្ធិមនុស្សជាបង្អែក ដោយទីភ្នាក់ងារជំនាញ កម្មវិធី និងស្ថាប័នរបស់អង្គការសហប្រជាជាតិនឹងជួយសំរួលដល់ការអនុវត្តសិទ្ធិទទួលការអប់រំឲ្យបានសំរេចគោលដៅផងដែរ។

## កំណត់សំគាល់

### */ មានចែងនៅក្នុងឯកសារ E/C. 12/1999/10.B

១. សេចក្តីថ្លែងការណ៍សកលលោកស្តីពីអប់រំសំរាប់ទាំងអស់គ្នាត្រូវបានអនុម័តដោយគណៈប្រតិភូរដ្ឋាភិបាលចំនួន ១៥៥ ប្រទេស។ សេចក្តីប្រកាស និងកម្មវិធីសកម្មភាពក្រុងវេទីសត្រូវបានអនុម័តដោយគណៈប្រតិភូរដ្ឋាភិបាលចំនួន ១៧១ ប្រទេស អនុសញ្ញាស្តីពីសិទ្ធិកុមារបានទទួលសច្ចាប័ន និងអនុម័ត ឬយល់ព្រមដោយរដ្ឋាភិបាលចំនួន ១៩១។ ផែនការសកម្មភាពនៃទសវត្សរ៍សហប្រជាជាតិសំរាប់អប់រំសិទ្ធិមនុស្សត្រូវបានអនុម័តដោយសេចក្តីសំរេចរួមមួយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ (៤៩/១៨៤)។

២. វិធីនេះឆ្លើយតបនឹងក្របខ័ណ្ឌសកម្មភាពវិភាគរបស់គណៈកម្មាធិការដែលបានអនុម័តទាក់ទងនឹងសិទ្ធិមានផ្ទះស្នាក់នៅ និងមានម្ហូបបរិភោគគ្រប់គ្រាន់ ក៏ដូចជាទាក់ទងនឹងរបាយការណ៍របស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិទទួលការអប់រំផងដែរ។ នៅក្នុងយោបល់ទូទៅលេខ ៤ គណៈកម្មា – ធិការក៏រកឃើញកត្តាជាច្រើនដែលមានចែងអំពីសិទ្ធិមានផ្ទះស្នាក់នៅ គិតទាំង "មានធនធានរូបវ័ន្ត" "មានលទ្ធភាពរកបាន" "មានលទ្ធភាពទទួល" និង"មានភាពគ្រប់គ្រាន់ផ្នែកវប្បធម៌"។ ក្នុងយោបល់ទូទៅលេខ ១៣ គណៈកម្មាធិការក៏បានរកឃើញខ្លឹមសារមួយចំនួនអំពីសិទ្ធិមានអាហារគ្រប់គ្រាន់ដូចជា "មានធនធានរូបវ័ន្ត""មានលទ្ធភាពរកបាន" និង"មានឱកាសចូលរៀន"។ នៅក្នុងរបាយការណ៍ដំបូងដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្សនូវរបាយការណ៍ពិសេសមួយស្តីពីសិទ្ធិទទួលការអប់រំ ដូចមានចែងក្នុង "កត្តាសំខាន់បួន ដែលសាលាបឋមសិក្សាគួរតែមានគឺ "មានធនធានរូបវ័ន្ត" "មានលទ្ធភាពរកបាន" "មានឱកាសចូលរៀន" និង "ងាយស្រួលកែប្រែឲ្យឆ្លើយតបនឹងតម្រូវការជាក់ស្តែង" (E/CN.4/1999/49 កថាខ័ណ្ឌ ៥០)។

៣. អានកថាខ័ណ្ឌ ៦

៤. សេចក្តីថ្លែងការណ៍មួយបានកំណត់និយមន័យពី"តម្រូវការរៀនសូត្រមូលដ្ឋានគ្រឹះ"ដូចជា អក្ខរកម្ម បញ្ចេញយោបល់ ចេះលេខនព្វន្ធ និងចេះដោះស្រាយបញ្ហា ហើយខ្លឹមសារមេរៀនមូលដ្ឋាន ដូចជាចំណេះដឹង ជំនាញ តម្លៃ ឥរិយាបថ ដែលមនុស្សគ្រប់រូបត្រូវការសំរាប់ការរស់នៅក្នុងសង្គមសំរាប់អភិវឌ្ឍសមត្ថភាពសំរាប់រស់នៅ និងធ្វើការក្នុងភាពថ្លៃថ្នូរ ចូលរួមយ៉ាងពេញទំហឹងក្នុងកិច្ចអភិវឌ្ឍន៍ លើកកំពស់គុណភាពជីវិតរបស់ប្រជាជនដើម្បីសំរេចចិត្តឲ្យបានត្រឹមត្រូវ និងបន្តការសិក្សា" (មាត្រា ១)។

៥. កញ្ចប់ឯកសារស្វែងរកការគាំទ្រមតិអំពីអប់រំមូលដ្ឋាន ១៩៩៩ (១៩៩៩ UNICEF)។

៦. អានកថាខ័ណ្ឌ ៦

៧. អានបំណែងចែកខ្នាតគំរូអប់រំអន្តរជាតិ ១៩៩៧ UNESCO កថាខ័ណ្ឌ ៥២

៨. ទស្សនៈមួយក៏បានយកមកពីអនុសញ្ញាអភិវឌ្ឍន៍ធនធានមនុស្ស ១៩៧៥ (អនុសញ្ញាលេខ ១៤២) និងគោលនយោបាយសង្គម (គោលបំណងមូលដ្ឋាន និងខ្នាតគំរូ) អនុសញ្ញា ១៩៦២ (អនុសញ្ញាលេខ ១១៧) របស់អង្គការពលកម្មកុមារអន្តរជាតិ។

៩. អានកថាខ័ណ្ឌ ៨

១០. អានកថាខ័ណ្ឌ ៦

១១. អានកថាខ័ណ្ឌ ១៥

១២. អានកថាខ័ណ្ឌ ៦

១៣. អានកថាខ័ណ្ឌ ៩

១៤. មាត្រានេះចំលងចេញពីមាត្រា ១៨ (៤) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ហើយទាក់ទងនឹងសេរីភាពក្នុងការបញ្ជ្រៀនសាសនា ឬជំនឿដូចមានចែងនៅក្នុងមាត្រា ១៨ (១) ICCPR។ អានយោបល់ទូទៅលេខ ២២ របស់គណៈកម្មាធិការសិទ្ធិមនុស្សនៅមាត្រា ១៨ ICCPR របស់សម័យប្រជុំលើកទី ៤៨ (ឆ្នាំ ១៩៩៣)។ គណៈកម្មាធិការសិទ្ធិមនុស្សកត់សំគាល់ថា ស្មារតីមាត្រា ១៨ ICCPR ឆ្លុះបញ្ចាំងការពិតដែលថា បញ្ញត្តិនេះមិនអាចដកស្រង់យកទៅកែច្នៃឲ្យខុសស្មារតីដើម ទោះបីក្នុងកាលៈទេសៈបន្ទាន់យ៉ាងណាក៏ដោយ ដូចមានចែងក្នុងមាត្រា ៤ (២) នៃកតិកាសញ្ញានោះ។

១៥. យោងតាមមាត្រា ២ : "នៅពេលរដ្ឋាភិបាលអនុញ្ញាត ស្ថានភាពខាងក្រោមនឹងមិនរួមចំណែកដល់ការរើសអើងឡើយ ស្របតាមស្មារតី និងអត្ថន័យរបស់មាត្រា ១ នៃអនុសញ្ញានេះ :

ក) ការបង្កើត ឬរក្សាប្រព័ន្ធអប់រំ ឬស្ថាប័នអប់រំឲ្យដាច់ដោយលែកសំរាប់សិស្សទាំងពីរភេទ លុះណាប្រព័ន្ធ ឬស្ថាប័នទាំងនោះធានាផ្តល់ការអប់រំឲ្យបានសមមូលគ្នាសំរាប់ភេទទាំងពីរ បណ្តុះបណ្តាលគ្រូឲ្យមានសមត្ថភាពតាមខ្នាតគំរូរួម រៀបចំឲ្យមានទីធ្លាសាលា និងសំភារៈប្រកបដោយគុណភាពដូចគ្នា ហើយក៏ត្រូវផ្តល់ឱកាសឲ្យសិស្សចាប់យកមុខវីជ្ជា ឬវគ្គសិក្សាដូចគ្នា ឬសមមូលគ្នា។

ខ) ការបង្កើត ឬរក្សាប្រព័ន្ធអប់រំ ឬស្ថាប័នអប់រំឲ្យដាច់ដោយលែកសំរាប់សាសនា ឬសំរាប់ភាសាកំណើត ជនជាតិដើម្បីផ្តល់ការអប់រំមួយតម្រូវចិត្តមាតាបិតា អាណាព្យាបាលសិស្ស លុះណាការចូលរៀនរបស់សិស្សក្នុងប្រព័ន្ធអប់រំ ឬស្ថាប័នអប់រំបែបនោះជាការបំពេញបន្ថែម ឬជាជំរើសបន្ថែម និងលុះណាការអប់រំនេះស្របតាមខ្នាតគំរូអប់រំដូចបានកំណត់ និងអនុញ្ញាតដោយអាជ្ញាធរមានសមត្ថភាពសំរាប់ការអប់រំក្នុងកំរិតដូចគ្នា។

គ) ការបង្កើត ឬរក្សាស្ថាប័នអប់រំឯកជន លុះណាស្ថាប័ននោះធានាថា គ្មានការរើសអើងប្រឆាំងនឹងក្រុមមនុស្សណា ប៉ុន្តែស្ថាប័ននោះត្រូវបំពាក់បរិក្ខាអប់រំបន្ថែមទៅលើបរិក្ខាដែលរដ្ឋបានផ្តល់ឲ្យ លុះណាស្ថាប័ននោះអនុវត្តតាមលក្ខខណ្ឌខាងលើ ហើយលុះណាស្ថាប័ននោះផ្តល់ការអប់រំដែលស្របតាមខ្នាតគំរូអប់រំដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចផ្នែកអប់រំ ជាពិសេស សំរាប់អប់រំនៅកំរិតដូចគ្នា។

១៦. អានអនុសាសន៍ UNESCO អំពីស្ថានភាពគ្រូបង្រៀននៅថ្នាក់ឧត្តមសិក្សា (១៩៩៧)

១៧. ក្នុងការគាក់តែងកថាខ័ណ្ឌនេះ គណៈកម្មាធិការបានកត់សំគាល់លើការអនុវត្តជាក់ស្តែងមួយចំនួនក្នុងប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ដូចជា ការបកស្រាយរបស់គណៈកម្មាធិការសិទ្ធិកុមារនៅក្នុងមាត្រា ២៨ (២) នៃអនុសញ្ញាសិទ្ធិកុមារ និងការបកស្រាយរបស់គណៈកម្មាធិការសិទ្ធិមនុស្សនៅមាត្រា ៧ របស់ ICCPR។

១៨. គណៈកម្មាធិការកត់សំគាល់ថា ទោះអវត្តមានពីមាត្រា ២៦ (២) នៃសេចក្តីប្រកាសពង្រាង ICESCRក៏បានបញ្ចូលខ្លឹមសារអំពីសេចក្តីថ្លៃថ្នូររបស់មនុស្សជាវត្ថុបំណងមួយដែលរាល់ការអប់រំទាំងអស់ត្រូវតែរួមចំណែកសំរេចឲ្យបាន (មាត្រា ១៣ (១))។

១៩. អានយោបល់ទូទៅលេខ ៣ កថាខ័ណ្ឌ ១

២០. អានយោបល់ទូទៅលេខ ៣ កថាខ័ណ្ឌ ២

២១. អានយោបល់ទូទៅលេខ ៣ កថាខ័ណ្ឌ ៩

២២. អានយោបល់ទូទៅលេខ ៣ កថាខ័ណ្ឌ ៩

២៣. មានធនធានជាច្រើនសំរាប់ជួយរដ្ឋាភិបាលក្នុងភារកិច្ចនេះ ដូចជា គោលការណ៍ណែនាំរបស់អង្គការ UNESCO សំរាប់រៀបរៀងកម្មវិធីសិក្សា និងសៀវភៅសិក្សាក្នុងការអប់រំអន្តរជាតិ (ED/ECS/HCI)។ ទិសដៅមួយនៃមាត្រា ១៣ (១) គឺសំដៅ "ពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពគ្រឹះ"។ ក្នុងបរិបទពិសេសបែបនេះ រដ្ឋាភិបាលគួរពិនិត្យ វិភាគគំនិតផ្តួចផ្តើមសកម្មភាពមានកំណត់នៅក្នុងក្របខ័ណ្ឌសកម្មភាពនៃទសវត្សរ៍សហប្រជាជាតិសំរាប់ការអប់រំសិទ្ធិមនុស្សជាពិសេស មានណែនាំច្បាស់នៅក្នុងផែនការសកម្មភាពសំរាប់ទសវត្សរ៍ដែលអនុម័តដោយមហាសន្និបាតឆ្នាំ១៩៩៦ និងគោលការណ៍ណែនាំសំរាប់ផែនការសកម្មភាពអប់រំសិទ្ធិមនុស្សដែលរៀបរៀងដោយការិយាល័យស្នងការជាន់ខ្ពស់សំរាប់សិទ្ធិមនុស្សសំរាប់ជួយរដ្ឋាភិបាលក្នុងការឆ្លើយតបនឹង សហាស្សវត្សរ៍សហប្រជាជាតិស្តីពីអប់រំសិទ្ធិមនុស្ស។

២៤. តាមអត្ថន័យនៃពាក្យ "ដោយកាតព្វកិច្ច" និង"ដោយឥតបង់ថ្លៃ" អានកថាខ័ណ្ឌ ៦ និង៧ នៃយោបល់ទូទៅលេខ ១១ ក្នុងមាត្រា ១៤។

២៥. ក្នុងករណីសមស្របមួយចំនួន ការបង្កើតប្រព័ន្ធអាហារូបករណ៍ក៏ជាមុខព្រួញសំរាប់ទាក់ទាញជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងមាត្រា ២ (១)។

២៦. ក្នុងបរិបទអប់រំមូលដ្ឋាន UNICEF បានអង្កេតឃើញថា : "មានតែរដ្ឋាភិបាលទេដែលអាចប្រមូលកំលាំងរួមដើម្បីបង្កើតប្រព័ន្ធអប់រំមួយដែលមានទំនាក់ទំនង និងទន់ភ្លន់" UNICEF របាយការណ៍ស្ថានភាពកុមារឆ្នាំ ១៩៩៩ "បដិវត្តន៍អប់រំ" ទំ. ៧៧។

២៧. យោងតាមមាត្រា ៧ (២) "ដោយពិចារណាលើសារៈសំខាន់នៃការអប់រំដើម្បីលុបបំបាត់ពលកម្មកុមារ រដ្ឋជាសមាជិកទាំងអស់ត្រូវចាត់វិធានការដែលមានប្រសិទ្ធភាព និងមានពេលវេលាកំណត់ច្បាស់លាស់ដើម្បី ក) ធានាផ្តល់ការអប់រំមូលដ្ឋានដោយឥតបង់ថ្លៃ ហើយបើអាចធ្វើបានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់កុមារទាំងអស់ដែលបានដកខ្លួនចេញពីពលកម្មកុមារក្នុងទម្រង់អាក្រក់បំផុត" អនុសញ្ញា IILO លេខ ១៨២ (ទម្រង់ពលកម្មកុមារអាក្រក់បំផុតឆ្នាំ ១៩៩៩)។

២៨. អានយោបល់ទូទៅលេខ ៣ របស់គណៈកម្មាធិការ កថាខ័ណ្ឌ ១៣ – ១៤

២៩. អានយោបល់ទូទៅលេខ ២ របស់គណៈកម្មាធិការ កថាខ័ណ្ឌ ៩


**បកប្រែអត្ថបទជាភាសាខ្មែរដោយ :**

លោក ឈិន និត NAATI Practitioner

**ផ្ទៀតផ្ទាត់ និង សំរួលអត្ថបទជាភាសាខ្មែរដោយ :**

លោក ខៀវ វិជ្ជានន្ទ

**ចែកចាយដោយ** UNESCO PHNOM PENH